# ឯកសារសង្ខេបស្ដីពី អ.វ.ត.ក ឧក្រិដ្ឋកម្មផ្លូវភេទ និង អនុសាសន៍ចេញមកពីវេទិកាការស្ដាប់សម្លេងពិតរបស់ស្ត្រីកម្ពុជា[i]

## សេចក្ដីសង្ខេប

1. ចំនួនភស្តុតាងកើនឡើងកាន់តែច្រើន បានបញ្ជាក់បង្ហាញថា អំពីឧក្រិដ្ឋកម្មផ្លូវភេទក្រោមរបបខ្មែរក្រហម គឺជាតថភាពកើតឡើងរាល់ថ្ងៃ ហើយការប្រព្រឹត្តិបែបនេះកម្រត្រូវគេយកទៅដាក់ទណ្ឌកម្មណាស់ និងបានទទួលការយល់ស្របឲ្យប្រព្រឹត្តដោយមិនចំហរមួយ តាមរយៈ "គោលនយោបាយកំចាត់ខ្មាំង" ហើយជនរងគ្រោះនៅមានជីវិត នៅតែបន្តទទួលរងការឈឺចាប់ពី ការប៉ះទង្គិចផ្លូវចិត្ត ការរើសអើង និងស្លាកស្នាមអប្រិយក្នុងសង្គមរហូតមកដល់សព្វថ្ងៃនេះ។
2. ទោះបីជាយ៉ាងនេះក្ដី ក៏ អ.វ.ត.ក នៅតែមានៈជាប់ជានិច្ចដោយមិនព្រមលើកយកឧក្រិដ្ឋកម្មផ្លូវភេទនេះ មកធ្វើការដេញដោលឲ្យបានពេញលេញនោះទេ ធ្វើឲ្យខកខានឱកាសក្នុងការបញ្ចូល និងធ្វើឲ្យរីកចម្រើនក្នុងពីមេរៀនដែលទទួលបាន ពីតុលាការក្នុងអតីតកាល (ដូចជា តុលាការព្រហ្មទណ្ឌអន្តរជាតិអតីតយូហ្គោស្លាវី, តុលាការព្រហ្មទណ្ឌអន្តរជាតិរវ៉ាន់ដា, តុលាការពិសេសសេរ៉ាឡេអូន ជាដើម) ទាំងក្នុងអភិក្រមផ្នែកតុលាការនិងទាំងក្នុងអភិក្រមមិនទាក់ទងបច្ចេកទេសតុលាការ។
3. តុលាការបានតម្រឹមខ្លួនតាមទស្សនៈដែលនឹងបន្តកើតមានយូរតទៅទៀតថា អំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហមមិនដែលកើតមានឡើងទេ ហើយថាប្រសិនបើមានកើតឡើងមែនអ្នកប្រព្រឹត្តនឹងត្រូវទទួលរងទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ។ ដូចនេះហើយ អ.វ.ត.ក មិនបានផ្ដល់អាទិភាពដល់ការស៊ើបអង្កេតបញ្ចូលគ្នានិងមានលក្ខណៈគ្រប់ជ្រុងជ្រោយនោះទេ ហើយភស្តុតាងដែលបានលើកឡើងកន្លងមក គឺជាលទ្ធផលដែលកើតចេញមកពីកិច្ចប្រឹងប្រែងរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីនិងមេធាវីរបស់ខ្លួន ក្នុងការអំពាវនាវដល់តុលាការឲ្យយកចិត្តទុកដាក់ទៅលើការស្ថានទម្ងន់ទោសនៃអំពើហិង្សាយេនឌ័រនេះ។ ប៉ុន្តែ ទោះបីជាការស៊ើបអង្កេតមិនទាន់មានលក្ខណៈជាប្រព័ន្ធនិងពេញលេញគ្រប់គ្រាន់នៅឡើយក្ដី ក៏នៅក្នុងដីកាដំណោះស្រាយសំណុំរឿង០០២ ក្នុងកថាខណ្ឌ១៤២៦-១៤២៩ បានបញ្ជាក់យ៉ាងច្បាស់ថា ទោះបីជាគោលនយោបាយរបបខ្មែរក្រហមមិនអាចគ្រប់គ្រងទប់ស្កាត់មិនឲ្យ

មានការរំលោភក៏ដោយ ក៏អំពើហិង្សាផ្លូវភេទក្រៅរង្វង់អាពាហ៍ពិពាហ៍ដោយបង្ខំ មិនត្រូវតុលាការពិចារណាថា របបនោះបានយកមកប្រើដើម្បីសម្រេចគោលបំណងរួមរបស់របបនេះឡើយ។ ហេតុដូច្នេះហើយ ជនត្រូវចោទមិនអាចទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មហិង្សាផ្លូវភេទក្រៅបរិបទការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ។

4. សារច្បាស់មួយក្នុងលក្ខណៈមិនបើកចំហរនេះ មានន័យថា និទណ្ឌភាពនៃអំពើហិង្សាផ្លូវភេទ ត្រូវបានការពារដោយស្ថាប័នច្បាប់ខ្ពស់បំផុតក្នុងប្រទេសកម្ពុជា។ បទពិសោធន៍ជាក់លាក់របស់ស្ត្រី មួយចំនួនដោយសារអំពើសហាវយង់ឃ្នង់ក្នុងរបបខ្មែរក្រហម មិនត្រូវបានគេរាប់បញ្ចូលនោះទេ ដូច្នេះហើយ រឿងរ៉ាវនេះនឹងមិនមានចំណែកនៅក្នុងកំណត់ត្រាប្រវត្តិសាស្ត្ររបបខ្មែរក្រហមជាផ្លូវការនោះទេ ដោយសារតែការកំណត់ក្នុងដំណើរការនីតិវិធី អ.វ.ត.ក។ បញ្ហានេះមានឥទ្ធិពលទាំងទៅលើបញ្ហាកេរដំណែលរបស់ អ.វ.ត.ក ទៅលើតុលាការជាតិក្នុងប្រទេសកម្ពុជា និងទាំងទៅលើការទទួលបានយុត្តិធម៌សម្រាប់ស្ត្រី ក៏ដូចជាលទ្ធភាពក្នុងការសម្រាប់បានការផ្សះផ្សារ សន្តិភាព និងសន្តិសុខសម្រាប់ស្ត្រីកម្ពុជា ដោយសារតែពួកគេនឹងទទួលការឈឺចាប់ដោយសារតែអំពើហិង្សាផ្លូវភេទបន្តរាលដាល និងស្លាកស្នាមអប្រិយធ្ងន់ធ្ងរនៃភាពដែលត្រូវគេធ្វើឲ្យរងគ្រោះនេះ។

5. នៅថ្ងៃទី៧-៨ ខែធ្នូ ២០១១ អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាបានរៀបចំវេទិកាមួយស្តីពី ការស្តាប់សម្លេងពិតរបស់ស្ត្រីកម្ពុជា រងគ្រោះដោយសារអំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហម រៀបចំនៅក្រុងភ្នំពេញនៃប្រទេសកម្ពុជា ដើម្បីទទួលស្គាល់ ទទួលដឹង និងទទួលយកជាផ្លូវការនូវបទពិសោធន៍ របស់សាក្សីនិងអ្នករស់រានមានជីវិតពីអំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហម។ អ្នកជំនាញមួយក្រុមបានបិទវេទិកាការស្តាប់សម្លងពិតរបស់ស្ត្រីនោះ ដោយបន្សល់ទុកនូវអនុសាសន៍មួយចំនួន ដល់ អ.វ.ត.ក ដល់អង្គការសហប្រជាជាតិ និង ដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីបំពេញនូវគណនេយ្យភាពក្នុងការដោះស្រាយបញ្ហាឧក្រិដ្ឋកម្មផ្លូវភេទនេះ ជាផ្នែកមួយនៃរបបខ្មែរក្រហម។ អនុសាសន៍ទាំងឡាយបានអំពាវនាវឲ្យមាន៖

    a. ការស៊ើបអង្កេតពេញលេញ និងការកាត់ទោស ដូចដែលបានអះអាងថាជាការពិត និងមាននៅក្នុងយុត្តាធិការអ.វ.ត.ក ទៅលើអំពើហិង្សាផ្លូវភេទ ដែលខ្មែរក្រហមបានប្រព្រឹត្ត

b. យន្តការសម្រាប់ការទទួលស្គាល់និងការផ្តល់សំណងសមរម្យ សម្រាប់ជនរងគ្រោះដោយអំពើហិង្សាផ្លូវភេទ ក្រោមរបបខ្មែរក្រហម
c. ការជម្រុញសមត្ថកិច្ចយេនឌ័រ និងការធ្វើឲ្យតុល្យភាពយេនឌ័រមានភាពប្រសើរឡើងនៅ អ.វ.ត.ក

6. ឯកសារសង្ខេបនេះផ្តល់ជូននូវទិដ្ឋភាពទូទៅមួយជាសារតារបស់ អ.វ.ត.ក ព្រមទាំង នីតិវិធី និងវិធីសាស្ត្ររបស់តុលាការនេះទាក់ទងនឹងហិង្សាផ្លូវភេទ។ ឯកសារនេះនឹងធ្វើការសន្និដ្ឋាន ដោយប្រើប្រាស់ការអំពាវនាវដែលកើតចេញមកពីវេទិកាស្តីពីការស្តាប់សម្លេងពិតរបស់ស្ត្រីកម្ពុជា ថា តាមរយៈភស្តុតាងដែលបានបង្ហាញថា អំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហមមានកើតនៅគ្រប់ទីកន្លែងនិងមានលក្ខណៈជាប្រព័ន្ធនោះ ឧក្រិដ្ឋកម្មនេះត្រូវទទួលបានផលប្រយោជន៍ពេញលេញពីធនធាននិងការយកចិត្តទុកដាក់របស់តុលាការ ដូចឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងៗទៀតនៅ ចំពោះមុខអ.វ.ត.ក។
7. ឯកសារនេះមានគោលបំណងផ្តល់ជូនអំពីជំហានជាក់លាក់រឹងមាំអាចអនុវត្តបាន ក្នុងការជម្រុញឲ្យដាក់បញ្ចូលឧក្រិដ្ឋកម្មផ្លូវភេទចូលទៅក្នុងរបៀបវារៈរបស់ អ.វ.ត.ក ក្នុងដំណើរការយុត្តិធម៌អន្តរកាលទាំងផ្នែកតុលាការ និងផ្នែកមិនទាក់ទងបច្ចេកទេសតុលាការ។

## ២. សាវតារ អ.វ.ត.ក

8. ក្នុងឆ្នាំ១៩៩៧ រដ្ឋាភិបាលកម្ពុជាបានស្នើសុំជំនួយពីអង្គការសហប្រជាជាតិ ក្នុងការបង្កើតតុលាការមួយសម្រាប់កាត់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលបានប្រព្រឹត្តិក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬ របបខ្មែរក្រហម។ បន្ទាប់ពីការចរចារអស់រយៈដ៏យូរ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា យល់ស្របក្នុងការបង្កើតតុលាការកូនកាត់មួយដែលនឹងដាក់បញ្ចូលគ្នានូវក្រុមចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រី ជាតិនិងអន្តរជាតិចម្រុះគ្នា ទោះបីជាមានទីតាំងស្ថិតក្នុងប្រព័ន្ធតុលាការកម្ពុជាក៏ដោយ។ បង្កើតឡើងក្រោមច្បាប់កម្ពុជាក្នុងឆ្នាំ២០០៤ តុលាការដែលបានបង្កើតឡើងនេះមានឈ្មោះថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រាប់កាត់ទោសឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តិឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (អ.វ.ត.ក)។

9. យុត្តាធិការ អ.វ.ត.ក គឺនាំមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតមកជំនុំជម្រះទៅលើបទចោទដែលបានប្រព្រឹត្តចន្លោះថ្ងៃ១៧ មេសា ១៩៧៥ ដល់ ថ្ងៃ៦ មករា ១៩៧៩។ ចំនួនជនរងគ្រោះដែលបានស្លាប់ក្នុងអំឡុងរបបខ្មែរក្រហម ត្រូវគេប៉ាន់ប្រមាណស្ថិតក្នុងចន្លោះពី ១.៧ ទៅ ២.២ លាននាក់ ឬ ពេញមួយភាគបួននៃចំនួនប្រជាជនសរុប។ តួលេខនេះត្រូវគេយល់ស្របគ្នាថាជាចំនួននៃការស្លាប់ធំជាងគេបំផុតកើតចេញពីវិនាសកម្មធ្ងន់ធ្ងរចាប់តាំងពីរបបប្រល័យពូជសាសន៍នៅអាឡឺម៉ង់ (Holocaust) ដូច្នេះហើយ វាក៏ជាការជំនុំជម្រះធំជាងគេបំផុតមួយដែរ ចាប់តាំងពីតុលាការនូរឹមប៊ឺក មក។ ភាគច្រើនបំផុតនៃអ្នកស្លាប់ និងអ្នកនៅរស់ គឺដោយសារតែ ការធ្វើពលកម្មដោយបង្ខំ ការផ្លាស់ប្តូរទីកន្លែងដោយបង្ខំ ភាពអត់ឃ្លាន ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការធ្វើទុក្ខបុកម្នេញលើសាសនា ការចាប់ខ្លួនតាមទំនើងចិត្ត អំពើទារុណកម្ម ឬ ការសម្លាប់ភ្លាមៗ។ ទីតាំងឧក្រិដ្ឋកម្មជាសក្តានុពល រួមមាន ប្រហែលជា គុកចំនួន២៨៩ កន្លែងពិឃាដចំនួន៣៨០ និងរណ្តៅសពរួមចំនួន១៩.៤០៣[ii]។

10. ច្បាប់ អ.វ.ត.ក ដែលជាការអនុវត្តកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងប្រទេសកម្ពុជា អនុញ្ញាតិឲ្យមានការអនុវត្តទាំងច្បាប់ជាតិនិងច្បាប់អន្តរជាតិនៅក្នុងតុលាការនេះ រួមមាន៖

    a. ឧក្រិដ្ឋកម្មដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ រួមមាន អំពើមនុស្សឃាដ អំពើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញលើសាសនា
    b. អំពើប្រល័យពូជសាសន៍ ដូចបានកំណត់នៅក្នុង អនុសញ្ញាឆ្នាំ១៩៤៨ស្តីពីការបង្ការនិងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍
    c. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ
    d. ឧក្រិដ្ឋកម្ម (បានប្រព្រឹត្តិឬបានបញ្ជាឲ្យប្រព្រឹត្តិ) នៃអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩
    e. អំពើបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ ក្នុងពេលមានជម្លោះប្រដាប់អាវុធ យោងតាមអនុសញ្ញាក្រុងឡាអេ ឆ្នាំ១៩៥៤ស្តីពីការការពារសម្បត្តិវប្បធម៌ក្នុងពេលមានជម្លោះប្រដាប់អាវុធ

f. ឧក្រិដ្ឋកម្មប្រឆាំងអ្នកដែលទទួលការការពារជាអន្តរជាតិ យោងតាម អនុសញ្ញាក្រុងវីយ៉ែន ឆ្នាំ១៩៦១ ស្តីពី ទំនាក់ទំនងការទូត [iii]

11. ទោះបីជាការរំលោភនិងអំពើហិង្សាផ្លូវភេទ ត្រូវបានរៀបចំចូលជាឧក្រិដ្ឋកម្មនៅក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ក៏ដោយ ក៏ឧក្រិដ្ឋកម្មផ្លូវភេទផ្សេងៗក្រៅពីការរំលោភ មិនត្រូវបានគេបញ្ចូលឲ្យបានច្បាស់លាស់នៅក្រោមច្បាប់ អ.វ.ត.ក ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។

12. ផ្នែកព្រះរាជអាជ្ញានិងផ្នែកតុលាការរបស់តុលាការនេះ មានការិយាល័យស៊ើបអង្កេតពីរនិងអង្គជំនុំជម្រះបី។ ការិយាល័យស៊ើបអង្កេតទាំងពីរ រួមមាន ការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើប ធ្វើការស៊ើបអង្កេតនិងរៀបចំការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ (កហព) និងដីកាដំណោះស្រាយ (កសច) ហើយដីកាដំណោះស្រាយនេះបង្កើតជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អង្គបុរេជំនុំជម្រះ (អបជ) បើកសវនាការលើការប្តឹងជំទាស់ពីដំណាក់កាលស៊ើបអង្កេត, អង្គជំនុំជម្រះសាលាដំបូង (អជស) បើកសវនាការទៅលើភស្តុតាងនៅក្នុងពេលជំនុំជម្រះ (បន្ថែមលើសេចក្តីសន្និដ្ឋានចាត់របៀប ទៅលើបញ្ហាខ្វែងយោបល់គ្នា), និងអង្គជំនុំជម្រះតុលាការកំពូល (អជត) បើកសវនាការនៃការប្តឹងជំទាស់ទាំងអស់ពីការសម្រេចចិត្តរបស់អង្គជំនុំជម្រះសាលាដំបូង។

13. ទាំងនៅក្នុងការិយាល័យនិងទាំងក្នុងអង្គជំនុំជម្រះ មានអតុល្យភាពយេនឌ័រយ៉ាងច្បាស់ដោយសារមិនមានស្ត្រីណាម្នាក់ដែលរដ្ឋាភិបាលកម្ពុជាបានតែងតាំងឲ្យទទួលតួនាទីជាចៅក្រមនៅតុលាការនេះឡើយ។ លោកជំទាវ ជាលាង សហព្រះរាជអាជ្ញាជាតិ (តាមបច្ចេកទេស ជា "ចៅក្រមថ្នាក់ក្រោម" ក្នុងប្រព័ន្ធបារាំង) គឺជាស្ត្រីកម្ពុជាតែមួយរូបគត់ស្ថិតក្នុងតួនាទីជាអ្នកដឹកនាំនៅក្នុងតុលាការនេះ។ ជាងនេះទៅទៀត ទាំងបុគ្គលិកជាតិនិងអន្តរជាតិធ្វើការក្នុងការស៊ើងបអង្កេត ភាគច្រើនបំផុតគឺជាបុរស ដោយមានព្រះរាជអាជ្ញាជាស្ត្រីតែ២រូបប៉ុណ្ណោះ និងបច្ចុប្បន្ននេះមិនមានស្ត្រីធ្វើការជាអ្នកស៊ើបអង្កេតនៅក្នុងតុលាការនេះឡើយ ហើយសម្រាប់បុគ្គលិកអង្គការសហប្រជាជាតិទាំងអស់វិញ មានស្ត្រីមិនដល់២០%ផង [iv]។ កង្វះខាតបុគ្គលិកស្ត្រីអាចរួមចំណែកដល់ឱនភាពយ៉ាងធ្ងន់ធ្ងរទាក់ទងនឹងសមត្ថភាពយល់ដឹងអំពីយេនឌ័រនៅក្នុងតុលាការនេះ ដោយបង្កឲ្យមានផលប៉ះពាល់រាំងសមត្ថភាពក្នុងការិយាល័យទាំងឡាយនៅ អ.វ.ត.ក ក្នុងការស៊ើបអង្កេតឲ្យបានពេញលេញទាក់

ទងនឹងឧក្រិដ្ឋកម្មយេនឌ័រ និងរារាំងមិនឲ្យសម្របបានតាមអភិក្រមរំញោចយេនឌ័រចំពោះច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ បញ្ហានេះក៏រួមបញ្ចូលអំពីសមត្ថភាពរបស់អ្នកស៊ើបអង្កេតក្នុងការសម្ភាសជនរងគ្រោះដែលបានលើកឡើងអំពីឧក្រិដ្ឋកម្មផ្លូវភេទ និងឧក្រិដ្ឋកម្មទាក់ទងនឹងយេនឌ័រ (ដែលភាគច្រើនជាស្ត្រី) ក៏ដូចជាសមត្ថភាពយល់ដឹងពេញលេញរបស់អ្នកស៊ើបអង្កេត អ្នកបកប្រែផ្ទាល់មាត់ អ្នកបកប្រែសរសេរ មេធាវី ចៅក្រម និងបុគ្គលិកផ្សព្វផ្សាយ អំពីការធ្វើឲ្យមានស្លាកស្នាមអប្រិយចិត្ត-សង្គម ទាក់ទងនឹងឧក្រិដ្ឋកម្មទាំងនោះ [v] ។

14. អ.វ.ត.ក គឺជាតុលាការអន្តរជាតិដោះស្រាយបញ្ហាឧក្រិដ្ឋកម្មធ្ងន់ធ្ងរទីមួយ ដែលអនុញ្ញាតិឲ្យជនរងគ្រោះចូលរួមជាភាគីដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណើរការនីតិវិធី និងទាមទារសំណងផ្លូវចិត្តនិងសំណងសម្ភារភាព។ លក្ខណៈពិសេសរបស់តុលាការនេះ ជាការចាំបាច់និងខានមិនបាន ក្នុងការលើកយកឧក្រិដ្ឋកម្មផ្លូវភេទដែលខ្មែរក្រហមបានប្រព្រឹត្ត ហើយគួរមានតួនាទីក្នុងការទាត់ចោលជំនឿដែលគេជឿយ៉ាងទូលំទូលាយថាអំពើហិង្សាផ្លូវភេទមិនបានកើតឡើងទេក្នុងរបបនោះ។ ជារឿយៗ ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះបានចេញមកបង្ហាញការពិត ដោយមានហានិភ័យខ្ពស់បំផុតសម្រាប់ខ្លួនឯង ជាពិសេសបន្ទុកដ៏សោកសង្រេងទាក់ទងនឹងអំពើហិង្សាផ្លូវភេទ ដោយសារតែស្លាកស្នាមអប្រិយធ្ងន់ធ្ងរទៅលើជនរងគ្រោះ សូម្បីតែរហូតដល់សព្វថ្ងៃនេះ។ ដោយសារតែ អ.វ.ត.ក មានលក្ខណៈពិសេសប្លែកពិសេស តាមរយៈការជំនុំជម្រះក្តីធ្វើឡើងក្នុងប្រទេសកម្ពុជានោះ ដំណើរការនីតិវិធីរបស់តុលាការមានផលប៉ះពាល់ដោយផ្ទាល់និងភ្លាមៗទៅលើអ្នករស់រានមានជីវិតនិងសាក្សី ដែលតុលាការនេះមានតួនាទីក្នុងការបន្សល់ទុកនូវកេរដំណែលដ៏ជ្រាលជ្រៅមួយសម្រាប់តុលាការជាតិកម្ពុជា ក៏ដូចជាបង្កើតករណីយុត្តិសាស្ត្រសម្រាប់តុលាការឧក្រិដ្ឋកម្មសង្គ្រាមដទៃទៀត [vi] ។

## សំណុំរឿងនៅចំពោះមុខ អ.វ.ត.ក

15. បច្ចុប្បន្ននេះ មានសំណុំរឿងចំនួនបួន នៅចំពោះមុខតុលាការ (សំដៅទៅលើសំណុំរឿង ០០១ សំណុំរឿង០០២ សំណុំរឿង០០៣ និងសំណុំរឿង០០៤) [vii] ។ ថ្មីៗនេះ ការប្តឹងជំទាស់របស់ជនត្រូវចោទ របស់សហព្រះរាជអាជ្ញា និងរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០១ កំពុងស្ថិតនៅក្នុងការរង់ចាំនៅតុលាការកំពូល ដែលការវិនិច្ឆ័យ

ចុងក្រោយ នឹងត្រូវប្រកាសនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២។ គួរកត់សម្គាល់ថា ក្នុងចំណោមបទចោទផ្សេងៗ ជនត្រូវចោទក្នុងសំណុំរឿង០០១ (កាំងហ្គិចអៀវ ហៅ ឌុច) ត្រូវបានដាក់ទោសលើបទមួយគឺការរំលោភដែលជាធាតុមួយនៃអំពើទារុណកម្មនៅគុក ស-២១ ដែលគាត់បានគ្រប់គ្រង។

However, on appeal by the Defense, the Supreme Court Chamber in February 2012 overturned the judgment of the Trial Chamber and ruled that 'rape' was not a distinct crime of crimes against humanity in April 1975 to January 1979.[viii]

16. សំណុំរឿង០០២ បានប្រកាសចាប់ផ្តើមដំណើរការនីតិវិធីក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ប្រឆាំងនឹងជនត្រូវចោទបីរូប ដែលជាតំណាងឲ្យថ្នាក់ដឹកនាំជាន់ខ្ពស់របស់រដ្ឋាភិបាលខ្មែរក្រហម។ សំណុំរឿង០០២ ត្រូវគេចាត់ទុកជាដំណាក់កាលដ៏សំខាន់ក្នុងច្បាប់អន្តរជាតិ ដោយសារតែទំហំនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងកម្រិតរបស់ចុងចោទ ហើយចំណុចនេះត្រូវបានលោក ស្តេហ្វិនរ៉ាប ឯកអគ្គរដ្ឋទូតអន្តរជាតិផ្នែកបញ្ហាឧក្រិដ្ឋកម្មសង្គ្រាម លើកឡើងថាជា"ការជំនុំជម្រះក្តីសំខាន់បំផុតក្នុងលោក" [ix] ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានគ្របដណ្តប់លើ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើទារុណកម្ម ការធ្វើទុក្ខបុកម្នេញលើសាសនា ការផ្លាស់ទីកន្លែងដោយបង្ខំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

17. ដើម្បីពន្លឿនដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានបំបែកសំណុំរឿងក្នុងសំណុំរឿង ០០២ ដោយសង្ឃឹមថា អាចសម្រេចបានយ៉ាងហោចណាស់ការវិនិច្ឆ័យចុងក្រោយមួយមុនពេលដែលជនត្រូវចោទស្លាប់បាត់បង់ជីវិតទៅ។ ជនត្រូវចោទទាំងបីមានអាយុចន្លោះ៧០ ទៅ ៨០ឆ្នាំហើយ គឺដូចគ្នានឹងជនរងគ្រោះនិងសាក្សីដែរ។ តាមពិតទៅ ជនត្រូវចោទទីបួន ត្រូវគេកំណត់ថាមិនមានកាយសម្បទាគ្រប់គ្រាន់ក្នុងការជំនុំជម្រះដោយសារតែហេតុផលសុខភាព។

18. ការជំនុំជម្រះដំបូងនៃសំណុំរឿង០០២ ផ្តោតតែមួយមុខគត់ទៅលើការចោទប្រកាន់លើអង្គហេតុ ដែលបានពណ៌នា នៅក្នុងដំណាក់កាលទីមួយនិងទីពីរនៃការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងដីកាដំណោះស្រាយសំណុំរឿង០០២។ អង្គជំនុំជម្រះ បានប្រមើលឃើញការជំនុំជម្រះបន្ថែមទាក់ទងនឹងភាពធ្ងន់ធ្ងរនៃសំណុំរឿង០០២ ដើម្បីពិភាក្សាអំពីឧក្រិដ្ឋកម្មដាច់ដោយឡែកពីគ្នារួមមាន អំពើប្រល័យពូជសាសន៍ ការធ្វើទុក្ខបុកម្នេញលើសាសនា

ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ព្រមទាំង អំពីមន្ទីរសន្តិសុខនិងការដ្ឋានផ្សេងៗ ទោះបីជាមិនទាន់មានភាពច្បាស់លាស់ថាមានការជំនុំជម្រះប៉ុន្មានដងទៀត ឬ អាចធ្វើនៅពេលនោះ នៅឡើយក្តី។

19. ការជំនុំជម្រះដំបូងត្រូវគេជឿថា ជាការជំនុំជម្រះតែមួយគត់ក្នុងសំណុំរឿង០០២នៅចំពោះមុខ អ.វ.ត.ក។ សំណុំរឿង០០១ ដែលគេយល់ថាជាការជំនុំជម្រះមិនសូវមានភាពស្មុគស្មាញ ចំណាយពេលអស់បីឆ្នាំដើម្បីបានដល់ទីបញ្ចប់។ ការជំនុំជម្រះដំបូងនៃសំណុំរឿង ០០២ មានជនត្រូវចោទបីរូប ដោយមិនមាននរណាម្នាក់សារភាពកំហុសទេ ហើយទាំងបីរូបសុទ្ធតែមានមេធាវីការពារដ៏រឹងមាំ។ ចំណុចនេះកាន់តែធ្វើឲ្យមានភាពកាន់តែអាក្រក់ទៅដោយសារតែវ័យរបស់ជនត្រូវចោទ ក៏ដូចជាពេលវេលាត្រូវការសម្រាប់ការពិភាក្សានិងការពិចារណា។

20. បន្ថែមលើនេះទៀត ទោះបីជាលក្ខន្តិកៈ អ.វ.ត.ក អនុញ្ញាតិឲ្យមានការកាត់ទោសសំណុំរឿង០០៣ និងសំណុំរឿង០០៤ក៏ដោយ ក៏សំណុំរឿងទាំងពីរនេះបានផុងចូលទៅក្នុងការចោទប្រកាន់អំពីការជ្រៀតជ្រែកនយោបាយ និងកំហុសវិជ្ជាជីវៈតុលាការ។ បញ្ហានេះក៏រួមមានការថ្លែងការណ៍យ៉ាងទទូចនិងដដែលៗ របស់នាយករដ្ឋមន្ត្រីកម្ពុជាលោកហ៊ុនសែន ដោយមានទាំងការថ្លែងដោយផ្ទាល់ទៅកាន់អគ្គលេខាអង្គការសហប្រជាជាតិ បានគីមូន ថា សំណុំរឿង០០៣ និង០០៤ "មិនត្រូវបានអនុញ្ញាតិ" និង នឹងមិនត្រូវអនុញ្ញាតិឲ្យយកទៅជំនុំជម្រះឡើយ[x] ។

## អ.វ.ត.ក និងឧក្រិដ្ឋកម្មអំពើហិង្សាផ្លូវភេទពេលមានជម្លោះ

21. អំពើហិង្សាផ្លូវភេទដែលបានប្រព្រឹត្តិចន្លោះថ្ងៃ១៧ មេសា ១៩៧៥ និង ៦ មករា ១៩៧៩ ដោយពួកខ្មែរក្រហម អាចត្រូវកំណត់លក្ខណៈជាអំពើអមនុស្សធម៌មួយ ឬ ការរំលោភ ហើយទាំងពីរនេះជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចដែលភស្តុតាងបានស្នើឡើងថា អំពើហិង្សានោះត្រូវបានប្រព្រឹត្តទៅលើប្រជាជនស៊ីវិល ហើយទង្វើនេះមិនស្ថិតនៅក្នុងបរិបទសង្គ្រាមប្រឆាំងវៀតណាមឡើយ។

22. តុលាការបានតម្រឹមខ្លួនតាមទស្សនៈដែលនឹងបន្តកើតមានយូរតទៅទៀតថា អំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហមមិនដែលកើតមានឡើងទេ ហើយថាប្រសិនបើមានកើតឡើងមែន

អ្នកប្រព្រឹត្តនឹងត្រូវទទួលរងទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ។ ដូចនេះហើយ តុលាការនេះមិនដែលបានការស៊ើបអង្កេតពេញលេញនិងជាក់ស្តែងទៅលើអំពើហិង្សាផ្លូវភេទទេ។ តាមពិតទៅ ចៅក្រមអង្គជំនុំជម្រះអន្តរជាតិ ស៊ីលវ៉ាខាតវ៉ាយ បានផ្តល់យោបល់នៅក្នុងវេទិកាសាធារណៈមួយថា យោងតាមភស្តុតាងដែលលោកស្រីបានជួបកន្លងមក របបខ្មែរក្រហមជារបបឧក្រិដ្ឋកម្មមួយក្នុងចំណោមរបបឧក្រិដ្ឋកម្មតិចតួចប៉ុណ្ណោះ ដែលអំពើហិង្សាទាក់ទងយេនឌ័រមិនមែនជាសកម្មភាពចម្បងសម្រាប់សកម្មភាពឧក្រិដ្ឋកម្មរបស់ខ្លួន[xi] ។

23. ជំនឿបែបនេះក៏មានផលប៉ះពាល់ដល់គណនេយ្យភាពដែរ។ ទោះបីជាឧទាហរណ៍អំពីអំពើហិង្សាផ្លូវភេទត្រូវបានបញ្ចូលក្នុងដីកាដំណោះស្រាយសំណុំរឿង០០២ក៏ដោយ ក៏ការិយាល័យសហចៅក្រមស៊ើបអង្កេតបានកំណត់ថា ជនត្រូវចោទមិនអាចត្រូវគេយកមកឲ្យទទួលខុសត្រូវឡើយ ពីព្រោះ ឧក្រិដ្ឋកម្មផ្លូវភេទត្រូវបានគេផ្តន្ទាទោសរួចហើយ ដូច្នេះមានន័យថា ខ្មែរក្រហមមានគោលបំណងទប់ស្កាត់មិនឲ្យមានអំពើហិង្សាផ្លូវភេទ ហើយថា វាមិនមែនជាគោលនយោបាយរបស់ខ្មែរក្រហមក្នុងការប្រើអំពើហិង្សាផ្លូវភេទប្រឆាំងនឹងជនរងគ្រោះនោះទេ[xii] ។

24. ប៉ុន្តែ ឧទាហរណ៍ពីរ នៅក្នុងដីកាដំណោះស្រាយ ដែលគេបានទាញបានជាសេចក្តីសន្និដ្ឋាននោះ មិនបានឆ្លុះបញ្ចាំងភស្តុតាងពេញលេញ ដោយយោងទៅតាមសេចក្តីថ្លែងរបស់សាក្សីឡើយ [xiii] ។ មានករណីរំលោភមួយពីកម្មាភិបាលខ្មែរក្រហម ត្រូវអាជ្ញាធរស៊ើបអង្កេត ប៉ុន្តែ លទ្ធផល គឺគេលើកលែងទោសឲ្យជនល្មើសនោះដោយសារតែគុណូបការបដិវត្ត។ ករណីទីពីរ ជនល្មើសដែលគេចោទប្រកាន់ ត្រូវបានចាប់ខ្លួនហើយត្រូវដោះលែងវិញពីរបីថ្ងៃក្រោយមក និងបន្តនៅក្នុងតួនាទីមានអំណាចដដែល ហើយទុកឲ្យជនរងគ្រោះស្ថិតក្នុងភាពអត់ឃ្លាននៅក្នុងគុក ជាការសងសឹករបស់ជនល្មើស។

25. ឧក្រិដ្ឋកម្មទាក់ទងនឹងអំពើហិង្សាផ្លូវភេទនិងអំពើហិង្សាទាក់ទងយេនឌ័រ មិនមែនជាការផ្តោតយកចិត្តទុកដាក់នៅក្នុងយុទ្ធសាស្ត្រកាត់ទោសតាំងពីដើមដំបូងសម្រាប់សំណុំរឿង០០១ នោះទេ។ ប៉ុន្តែ បន្ទាប់ពីការលើកកម្ពស់ការយល់ដឹងនិងការតស៊ូមតិក្នុងអំឡុងដំណាក់កាលស៊ើបអង្កេត ដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី រួមជាមួយនិងការរកឃើញភស្តុតាងសម្រាប់បទចោទនេះ ការចោទប្រកាន់អង្គហេតុទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បានលេចឡើងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើជនត្រូវចោទក្នុងសំណុំរឿង០០២

នៅក្រោមគោលនយោបាយទីប្រាំរបស់ពួកខ្មែរក្រហមថាជា "បទបញ្ញារៀបអាពាហ៍ពិពាហ៍" [xiv] ។

26. មានទឡ្ហីករណ៍សំខាន់ៗបីដែលបានលើកឡើងយ៉ាងច្បាស់ថាឧក្រិដ្ឋកម្មផ្លូវភេទ គួរតែនិងត្រូវតែបាន អ.វ.ត.ក ពិចារណា ដោយអាស្រ័យទៅ ភាពញឹកញាប់ ភាពធ្ងន់ធ្ងរនិងនិទណ្ឌភាព ទាក់ទងនឹងអំពើទាំងនេះ។ ទឡ្ហីករណ៍ទាំងបីមានដូចខាងក្រោមៈ

## ក. គោលនយោបាយខ្មែរក្រហមប្រឆាំងនឹងការរំលោភបំពានលើស្ត្រី (ដែលគេហៅថា "បទល្មើសសីលធម៌) មិនត្រូវបានគេអនុវត្តឲ្យបានតឹងរ៉ឹង ឬ ឯកភាពគ្នានោះទេ

27. មេដឹកនាំខ្មែរក្រហមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានប្រកាសឲ្យប្រើប្រាស់គោលនយោបាយ "សីលធម៌ប្រការទី៦" ក្នុងចំណោម "សីលធម៌១២ប្រការរបស់ជនបដិវត្ត"។ សីលធម៌ប្រការទី៦ ចែងថាៈ

> កុំប្រព្រឹត្តអ្វីឲ្យល្មើសនឹងស្ត្រីភេទឲ្យសោះ (បង្ខំស្ត្រីឲ្យព្រមរួមភេទ ឬការរួមភេទជាមួយស្ត្រីដែលមិនមែនជាប្រពន្ធរបស់ខ្លួន [xv] ។

28. វត្តមាននៃសីលធម៌ប្រការទី៦ ដែលជាទូទៅគេហៅថាជាក្រឹត្យវិន័យអំពើ "បទល្មើសសីលធម៌" នោះ បាននាំឲ្យមនុស្សមួយចំនួនលើកឡើងថា គោលនយោបាយនេះត្រូវបានគេអនុវត្តជាប្រចាំ ដោយមានការដាក់ទណ្ឌកម្មលើជនខុសសីលធម៌ ហើយថា ការហាមឃាត់លើអំពើសីលធម៌នេះ បានទប់ស្កាត់ឬរាំងមិនឲ្យអំពើហិង្សាផ្លូវភេទនេះកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ។

29. ប៉ុន្តែ នៅមានមន្ទិលសង្ស័យថាតើ សីលធម៌ប្រការទី៦នោះ ពិតជាត្រូវគេប្រើសំដៅទៅលើ ឬជាការទប់ស្កាត់ ការរំលោភបំពានផ្លូវភេទដែលកម្មាភិបាលខ្មែរក្រហមបានប្រព្រឹត្តមែនឬក៏អត់នោះទេ។ មើលទៅហាក់ដូចជា សីលធម៌ប្រការទី៦នេះ មានចេតនាហាមឃាត់មិនឲ្យមានទំនាក់ទំនងផ្លូវភេទក្រៅអាពាហ៍ពិពាហ៍ ទោះជាមានការយល់ព្រមឬមិនយល់ព្រមក៏ដោយ ហើយភាគីទាំងពីរអាចនឹងត្រូវរងទណ្ឌកម្ម។ ដូចនេះហើយ នៅក្នុងករណីនៃទំនាក់ទំនងមិនមានការយល់ព្រមជាមួយគ្នា ទាំងជនរងគ្រោះ ទាំងជនល្មើសត្រូវទទួលទណ្ឌកម្ម [xvi] ។ ក្នុងន័យជាក់ស្តែង វិន័យអំពី "បទល្មើសសីលធម៌" នេះ មិនសូវមានការពាក់

ព័ន្ធនឹងការការពារប្រឆាំងអំពើហិង្សាផ្លូវភេទដោយភាគីរដ្ឋនោះទេ ហើយវិន័យនេះ អាចជាប់ពាក់ព័ន្ធជាមួយនឹងការដាក់កម្រិតទៅលើសកម្មភាពផ្លូវភេទ ជាផ្នែកមួយនៃការដាក់ការគ្រប់គ្រងទំនាក់ទំនងមនុស្សទាំងអស់ ឲ្យត្រូវតាមគោលបំណងបដិវត្ត ច្រើនជាង។

30. ប្រសិនបើសីលធម៌ប្រការទី៦នេះ ត្រូវគេបកស្រាយជាចម្បងថា ជាមធ្យោបាយ សម្រាប់ដាក់កម្រិតលើសកម្មភាពផ្លូវភេទ និងសម្រាប់ធានាថាវាស្របនឹងគោលបំណងបដិវត្តនោះ គោលនយោបាយដែលគាំទ្រសីលធម៌នេះ អាចត្រូវបកស្រាយដោយយោងទៅតាមទឡ្ហីករណ៍បីខាងក្រោមនេះ៖

    1) ទំនាក់ទំនងផ្លូវភេទត្រូវគេយល់ថាមានលក្ខណៈជាការបំផ្លាញ គំរាមកំហែង បង្អាក់ប្រជាជនមិនឲ្យធ្វើការងារឆ្ពោះទៅសម្រេចបានបដិវត្តទាំងស្រុង
    2) សីលធម៌នេះត្រូវគេមើលឃើញថាជាដំណើរស្វែងរកការបង្កើតឲ្យមានជាតិខ្មែរ "សុទ្ធ" មួយ ដែលគេបានអនុវត្តបន្ថែមតាមរយៈគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ
    3) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរៀបចំឡើងដោយ *អង្គការ* (គណៈកម្មាធិការអចិន្ត្រៃយ៍ ដែលជាអង្គភាពខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យ) ត្រូវគេលើកទឹកចិត្តឲ្យបង្កើនចំនួនជនបដិវត្តរបស់ជាតិសុទ្ធមួយ ឲ្យដល់បួនដង ក្នុងរយៈពេល១៥-២០ឆ្នាំ [xvii] ។

31. **ការសន្មតថាការរំលោភត្រូវគេដាក់ទណ្ឌកម្ម៖** មានការសន្មតដោយខុសឆ្គងជាសកលក្នុងចំណោមអ្នកស្រាវជ្រាវជាច្រើន និងដូចបានឆ្លុះបញ្ចាំងក្នុងដីកាដំណោះស្រាយសំណុំរឿង០០២[xviii] ថា យោងតាមសីលធម៌ប្រការទី៦ ការរំលោភក្នុងរបបខ្មែរក្រហមកម្រកើតមានណាស់ ហើយថាប្រសិនបើមានកើតឡើងមែន អ្នកប្រព្រឹត្តនឹងត្រូវទទួលរងទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ។ ប៉ុន្តែ យ៉ាងហោចណាស់មានស្ថានភាពពីរដែលសីលធម៌ប្រការទី៦នេះ មិនអាចឲ្យគេអនុវត្តបាន៖

    a. ប្រសិនបើអំពើហិង្សានេះ ត្រូវគេប្រព្រឹត្តទៅលើបុគ្គលដែលគេកំណត់ថាជា "ខ្មាំង" របស់បដិវត្តនោះ មានន័យថា ជនរងគ្រោះនេះមិនត្រូវបានការពារដោយគោលនយោបាយឡើយ

b. ប្រសិនបើជនល្មើសអាចបញ្ជាក់បង្ហាញនូវ ប្រវត្តិរូប "ជាជនបដិវត្តល្អ" មួយរូបនោះ មានន័យថា ពួកគេអាចទទួលការលើកលែងទោស និងមិនចាំបាច់ទទួលទណ្ឌកម្មទេ [xix]។

32. ភស្តុតាងនេះលើកឡើងថា ក្នុងទម្រង់មួយដែលបទល្មើសប្រព្រឹត្តឡើងប្រឆាំងនឹងបដិវត្ត អំពើហិង្សាផ្លូវភេទ ជាពិសេសការរំលោភ ត្រូវគេចាត់ទុកថាជាបទល្មើសស្រាលដោយពួកខ្មែរក្រហម។ ស្របគ្នានេះ មិនមានស្ថាប័នផ្លូវការឬក្រៅផ្លូវការណាមួយ (ក្នុងទម្រង់ជាតុលាការ ប៉ូលីស ជាដើម) សម្រាប់ជនរងគ្រោះស្វែងរកសំណង ឬការទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មនៃអំពើហិង្សាផ្លូវភេទនោះទេ។ ទោះបីជាមានឬមិនមានសីលធម៌ប្រការទី៦ក៏ដោយ ក៏ "ការរំលោភ" ត្រូវគេចាត់ទុកជាសកលថា ជាឧក្រិដ្ឋកម្មនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយតាមពិតទៅ ត្រូវបានបញ្ចូលនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលមេដឹកនាំខ្មែរក្រហមទាំងឡាយ និងប្រជាជនទាំងអស់ បានដឹងឮ។

33. **ការសន្និដ្ឋានអំពីកង្វះភស្តុតាង៖** បន្ថែមពីលើនេះទៀត ភស្តុតាងបឋមដែលការិយាល័យសហព្រះរាជអាជ្ញាប្រមូលបាន បាននាំឲ្យការិយាល័យនេះសន្និដ្ឋានថា ដោយសារតែសីលធម៌ប្រការទី៦ ត្រូវគេអនុវត្តដោយតឹងរ៉ឹងនោះ ករណីឧក្រិដ្ឋកម្មផ្លូវភេទមិនបានកើតឡើងទេ។ ដូច្នេះហើយ ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនបានចាប់យកការស៊ើបអង្កេតណាមួយទៅលើអំពើហិង្សាផ្លូវភេទឡើយ។ តាមពិតទៅ ការស៊ើបអង្កេតបន្ទាប់ពីរបបខ្មែរក្រហមដួលរលំភ្លាម មិនបានបញ្ចូលឧក្រិដ្ឋកម្មផ្លូវភេទទេ និងមានការខ្វះខាតវិធីសាស្ត្រធ្វើកោសល្យវិច័យក្នុងការបង្កើតមូលដ្ឋានថាឧក្រិដ្ឋកម្មទាំងនោះបានកើតឡើង [xx]។

34. ខណៈពេលដែលជនរងគ្រោះភាគច្រើនត្រូវគេសម្លាប់បន្ទាប់ពីការរំលោភបានកើតឡើង (ឬក្រោយមកស្លាប់ដោយសារជម្ងឺ ភាពអត់ឃ្លាន ជាដើម) នោះ ការស្រាវជ្រាវដែលមានចំនួនកើនឡើង បានបញ្ជាក់បង្ហាញថា អំពើហិង្សាផ្លូវភេទមានកើតឡើងនៅគ្រប់កន្លែងក្នុងអំឡុងរបបខ្មែរក្រហម ហើយថា អ្នកនៅរស់រានមានជីវិត និងសាក្សីនៃអំពើហិង្សាផ្លូវភេទជាច្រើន នៅមានវត្តមាន និងមានឆន្ទៈក្នុងការចេញមុខមកចែករំលែករឿងរបស់ខ្លួន។ ជាងនេះទៅទៀត ការស្រាវជ្រាវថ្មីៗអំពីអំពើហិង្សាផ្លូវភេទក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានលើកឡើងថា គោលនយោបាយប្រឆាំងនឹង "បទល្មើសសីលធម៌" មិនបានទប់ស្កាត់មិនឲ្យកើតឡើងនូវអំពើហិង្សាផ្លូវភេទនៅគ្រប់ទីកន្លែងនោះឡើយ ហើយថា មានឧទាហរណ៍ជា

ច្រើនទាក់ទងនឹងករណីនេះ ដែលមិនបានទទួលទណ្ឌកម្ម ទោះបីជាអាជ្ញាធរបានដឹងឮក៏ដោយ [xxi] ។

## ខ. គោលនយោបាយខ្មែរក្រហមក្នុងការជម្រុះ "សមាសភាពមិនល្អ" និង "ខ្មាំង" អនុញ្ញាតិឲ្យការរំលោភនិងអំពើហិង្សាផ្លូវភេទ កើតឡើងចំពោះជនដែលគេយល់ថាជាខ្មាំង ដោយគ្មានទោសពៃរ៍

35. នៅក្នុងដីកាដំណោះស្រាយសំណុំរឿង០០២ ការិយាល័យសហចៅក្រមស៊ើបបានចោទថា ខ្មែរក្រហមបានបង្កើតគោលនយោបាយនៃការអប់រំឡើងវិញទៅលើ "សមាសភាពមិនល្អ" និង ការសម្លាប់ "ខ្មាំង" ទាំងក្នុងនិងក្រៅជួរបក្ស តាម "គ្រប់វិធីដែលចាំបាច់"។ ដីកាដំណោះស្រាយបញ្ចូលបន្ថែមអំពី ការចាប់ ការសួរចម្លើយ ការធ្វើទារុណកម្ម និងការសម្លាប់ នៅក្នុងនិយមន័យនៃពាក្យ "គ្រប់វិធីដែលចាំបាច់"។ ដីកាដំណោះស្រាយ មិនមានលើកឡើងអ្វីសោះ ទាក់ទងនឹងអំពើហិង្សាផ្លូវភេទថា ជាចំណែកនៃគោលនយោបាយនេះទេ ទោះបីជាមានភស្តុតាងលើកឡើងថាអំពើហិង្សាផ្លូវភេទត្រូវគេប្រើជាការបញ្ជាក់បង្ហាញអំណាច និងការដាក់ទណ្ឌកម្ម ទៅលើអ្នកដែលត្រូវគេគិតថាជាខ្មាំងឬជាសមាសភាពមិនល្អ និងទៅលើអ្នកមានការជាប់ពាក់ព័ន្ធជិតស្និទ្ធ ជាខ្មាំង ឬជាសមាសភាពមិនល្អ។ ដូចនេះហើយ ទោះបីជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលជាទម្រង់មួយនៃអំពើហិង្សាទាក់ទងយេនឌ័រ ត្រូវគេបញ្ចូលក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០២ក៏ដោយ (ខាងមើលខាងក្រោម) ក៏មេដឹកនាំជាន់ខ្ពស់ទាំងនោះ មិនត្រូវគេដាក់ឲ្យទទួលខុសត្រូវចំពោះអំពើហិង្សាផ្លូវភេទ និងការរំលោភនៅក្រៅរង្វង់អាពាហ៍ពិពាហ៍ដែរ ទោះជាមានការចោទប្រកាន់លើអង្គហេតុសម្រាប់ករណីមួយចំនួនទាក់ទងនឹងអំពើហិង្សាផ្លូវភេទនេះ ត្រូវគេបញ្ចូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក៏ដោយ។ វាអាស្រ័យទៅលើអង្គជំនុំជម្រះក្នុងការពិចារណាឡើងវិញអំពីរបកគំហើញអំពីការទទួលខុសត្រូវ ចេញពីការិយាល័យសហចៅក្រមស៊ើបអង្កេត [xxii] ។

36. ការដែលការិយាល័យសហចៅក្រមស៊ើបអង្កេតទាត់ចោលបទល្មើសអំពើហិង្សាផ្លូវភេទ ចេញពីដីកាដំណោះស្រាយសំណុំរឿង០០២នេះ ជាការបរាជ័យក្នុងការពិចារណាសមាសភាពសំខាន់ៗដូចខាងក្រោមនៃគោលនយោបាយខ្មែរក្រហមដែលអាចអនុញ្ញាតិដោយមិនចំហាឲ្យមានអំពើហិង្សាផ្លូវភេទកើតឡើង៖

a. ប្រសិនបើការហាមឃាត់មិនឲ្យបំពានស្ត្រីនៃសីលធម៌ប្រការទី៦ មិនអនុវត្តទៅលើអ្នកដែលគេកំណត់ថាជា "សមាសភាពមិនល្អ" ឬ "ខ្មាំង" នោះ មានន័យថា អ្នកដែលជាគោលដៅនៃការចាប់ខ្លួន ការអប់រំឡើងវិញ ការចាប់ដាក់គុក ការធ្វើទារុណកម្ម ឬការសម្លាប់នោះ តាមព្រឹត្តហេតុ ត្រូវគេដកហូតភាពជាមនុស្ស ហើយជាលទ្ធផលអាចទទួលរងការធ្វើអំពើហិង្សាផ្លូវភេទមកលើ ខណៈដែលជនដៃដល់នឹងមិនមានការភ័យថានឹងទទួលទណ្ឌកម្មឡើយ។

b. អំពើហិង្សាផ្លូវភេទដែលគេប្រើប្រឆាំងនឹងខ្មាំង មិនដែលត្រូវគេហាមឃាត់ ឬដាក់ទណ្ឌកម្មឡើយ។ ក្នុងសំណុំរឿង០០១ ជនត្រូវចោទ ដែលជាអ្នកដឹកនាំមន្ទីរស-២១ ត្រូវគេចោទពីបទរំលោភមួយដែរ។ ជនត្រូវចោទ បានផ្តល់សក្ខីកម្មថា គាត់បានជូនដំណឹងដល់សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលជាអង្គភាពធ្វើសេចក្តីសម្រេចចិត្តខ្ពស់ជាងគេរបស់ខ្មែរក្រហម មួយរូប អំពីការរំលោភនេះ។ ប៉ុន្តែ គាត់មិនបានបញ្ជាឲ្យមានការដាក់ទណ្ឌកម្មទៅលើជនដៃដល់នោះទេ ដែលនេះវាស្របទៅតាមការមិនដាក់ទណ្ឌកម្មពីគណៈកម្មាធិការអចិន្ត្រៃ នៅពេលទទួលបានការរាយការណ៍អំពីករណីនេះ [xxiii]។ ឧទាហរណ៍នេះបញ្ជាក់ថា យ៉ាងហោចណាស់មានករណីមួយដែលបុគ្គលម្នាក់ត្រូវគេចាត់ទុកថាជា "ខ្មាំង" ក្នុងករណីនេះអាចកើតឡើងទៅលើអ្នកជាប់ឃុំឃាំងនៅមន្ទីរស-២១ទាំងអស់ ហើយថាអំពើហិង្សាផ្លូវភេទអាចត្រូវគេប្រើប្រឆាំងនិងអ្នកទោសខណៈដែលជនដៃដល់នឹងមិនទទួលទណ្ឌកម្មសោះឡើយ។ ចំណុចនេះក៏បានលើកឡើងបន្ថែមទៀតថា សមាជិកជាន់ខ្ពស់នៃរបបខ្មែរក្រហម អាចមានហេតុផលក្នុងការដឹងឮអំពីការប្រព្រឹត្តអំពើហិង្សាផ្លូវភេទដែលគេប្រព្រឹត្តទៅលើ "ខ្មាំង" នេះបន្ថែមទៀត ហើយអាចខកខានមិនបានទប់ស្កាត់ឬដាក់ទណ្ឌកម្មអ្នកប្រព្រឹត្តនៅរឿងនេះកើតឡើង។

c. តួអង្គរដ្ឋនៅថ្នាក់ដឹកនាំកម្រិតខ្ពស់បំផុតរបស់ខ្មែរក្រហម បានដឹង ឬ គួរតែបានដឹង ថា អំពើហិង្សាផ្លូវភេទត្រូវគេប្រព្រឹត្តដោយគ្មានទទួលទោសពៃរ៍ទៅលើ "ខ្មាំង" ឬ "សមាសភាពមិនល្អ"។ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានកំណត់ថា ជនត្រូវចោទក្នុងសំណុំរឿង០០២នេះ បានបង្កើតនិងប្រកាសឲ្យប្រើ

គោលនយោបាយប្រឆាំងនឹង "ខ្មាំង" ឬ "សមាសភាពមិនល្អ" [xxiv]។ តាមរយៈការបង្កើតគោលនយោបាយនេះ មេដឹកនាំជាន់ខ្ពស់ដែលទទួលរងការចោទប្រកាន់ បានបើកទ្វារឲ្យមានវប្បធម៌និទណ្ឌភាព សម្រាប់ការប្រព្រឹត្តបែបអមនុស្សធម៌ប្រឆាំងនឹងខ្មាំង។ លើសពីនេះទៀត ដើម្បីកម្ចាត់ "ខ្មាំង" ទាំង "ឫស" គេកំណត់ធ្វើយ៉ាងណាឲ្យគ្រួសារនិងអ្នកជាប់ទាក់ទងជិតស្និទ្ធត្រូវមានពាក់ព័ន្ធ សម្រាប់ការដាក់ទណ្ឌកម្មទៅលើខ្មាំងដែរ។ ក្នុងន័យនេះ ជារឿយៗ ស្ត្រីក្លាយជាគោលដៅនៃអំពើហិង្សាផ្លូវភេទនេះ នៅពេលគេចោទប្ដីថាជាចារកិច្ច ឬពីបទចូលរួមក្នុងសកម្មភាពផ្សេងៗជាមួយខ្មាំង [xxv]។

d. ភស្តុតាងពិតជាមានជាក់ស្ដែង ដោយរាប់ទាំងភស្តុតាងថ្មីៗនៅចំពោះមុខអង្គជំនុំជម្រះ និងក្នុងករណីសំណុំរឿង០០២ រាប់រយទំព័រ ថាអំពើហិង្សាផ្លូវភេទកើតឡើងនៅគ្រប់ទីកន្លែង ហើយជាសមាសធាតុស្នូលមួយក្នុងគោលនយោបាយខ្មែរក្រហមប្រឆាំងនឹងខ្មាំង ហើយថាអាជ្ញាធរបានដឹងអំពីការកើតឡើងទាំងនេះ ហើយដឹងថាអំពើហិង្សាទាំងនេះត្រូវគេអនុវត្តដោយគ្មានទោសពៃរ៍អ្វីទាំងអស់។

## គ. គោលនយោបាយខ្មែរក្រហមអំពី ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មានភាពដូចគ្នាអំពើហិង្សាផ្លូវភេទយ៉ាងជាក់ច្បាស់ ទោះបីជាចារិកលក្ខណៈផ្លូវច្បាប់នៅមានភាពមិនច្បាស់ក៏ដោយ

37. គោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្រោមរបបខ្មែរក្រហម ដែលបុគ្គលត្រូវគេចាត់ឲ្យក្លាយជាប្ដី/ប្រពន្ធ និងរៀបការជាក្រុមមានរហូតដល់រាប់រយគូនោះ ត្រូវបានអ្នកប្រវត្តិសាស្ត្រនិងអ្នកស្រាវជ្រាវដឹងឮគ្រប់គ្នា។ ប៉ុន្តែការស៊ើបអង្កេតទៅលើការអនុវត្ត មិនមានចំណែកនៅក្នុងយុទ្ធសាស្ត្រកាត់ទោសពីដំបូងរបស់ អ.វ.ត.ក ឡើយ ដោយសារតែគេមិនបានចាត់ទុកថាវាជាឧក្រិដ្ឋកម្ម។ ការដាក់ពាក្យសុំតាំងខ្លួនជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីទៅក្នុងតុលាការនេះ បានលើកកម្ពស់ការយល់ដឹងអំពើទម្ងន់និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ហើយមេធាវីភាគីដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់សេចក្ដីសន្និដ្ឋានផ្លូវច្បាប់ជាច្រើនទៅកាន់អង្គជំនុំជម្រះសាលាដំបូង ស្នើសុំឲ្យចាត់ទុកការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមានតម្លៃផ្លូវច្បាប់ជា ការរំលោភ ការដាក់ឲ្យទៅជាទាសករ អំពើទារុណកម្ម ក៏ដូចជា ចាត់ទុកថា

ជាឧក្រិដ្ឋកម្មដាច់ដោយឡែកមួយអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការបង្ខំឲ្យមានផ្ទៃពោះ ដូចអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ [xxvi] ។

38. ជាលទ្ធផលនៃកិច្ចប្រឹងប្រែងនេះ ក្នុងឆ្នាំ២០០៩ ការិយាល័យសហព្រះរាជអាជ្ញាបានចាត់ឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត ចាត់ការរឿងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះ ត្រូវគេបញ្ចូលជាផ្នែកមួយនៃដីកាដំណោះស្រាយសំណុំរឿង០០២។ បន្ថែមលើនេះទៀត តុលាការបានទទួលស្គាល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីចំនួន៧៨០នាក់ ដែលបានទទួលរងការឈឺចាប់ដោយសារតែបទចោទមួយនេះ ហើយបានបង្កើតជាក្រុមភាគីដើមបណ្តឹងរដ្ឋប្បវេណីធំជាងគេទីពីរ។ ក្រុមដែលធំជាងភាគីដើមបណ្តឹងរដ្ឋប្បវេណីចោទប្រកាន់ពីបទរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះ គឺក្រុមភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលមានសមាជិក៧៨១រូប លើមូលដ្ឋាននៃការផ្លាស់ប្តូរទីកន្លែងដោយបង្ខំ ក្នុងចំណោមប្រជាជនទាំងអស់នៅក្រុងភ្នំពេញក្នុងខែមេសា ១៩៧៥។

39. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ លេចឡើងក្នុងដីកាដំណោះស្រាយ ជាគោលនយោបាយមួយក្នុងចំណោមគោលនយោបាយទាំងប្រាំរបស់របបខ្មែរក្រហម ដោយមានដាក់ចំណងជើងថា "បទបញ្ជារៀបអាពាហ៍ពិពាហ៍"។ ពាក្យនេះបានកាត់បន្ថយយ៉ាងខ្លាំងនូវផលប៉ះពាល់ពហុវិស័យ និងភាពធ្ងន់ធ្ងរខ្លាំងនៃឧក្រិដ្ឋកម្មនេះ។ គេប៉ាន់ប្រមាណថាមនុស្សរាប់សែននាក់ទាំងបុរសនិងស្ត្រី បានទទួលរងផលប៉ះពាល់នៃគោលនយោបាយនេះ និងត្រូវគេបង្ខំឲ្យមានទំនាក់ទំនងជាប្តីប្រពន្ធខុសពីឆន្ទៈរបស់ខ្លួន។ ការបដិសេធ នាំឲ្យមានការដាក់ទណ្ឌកម្ម ការចាប់ដាក់គុក ជួនកាលត្រូវស្លាប់ និងការលាបពណ៌ថាជា "សមាសភាពមិនល្អ" ឬ "ខ្មាំង"។

40. ស្ថានភាពនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងប្រទេសកម្ពុជា មិនមានករណីយុត្តិសាស្ត្រពីមុនមកនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិនោះទេ។ ដោយសារតែគូអាពាហ៍ពិពាហ៍ថ្មីថ្មោង ត្រូវគេបង្ខំឲ្យរួមដំណេក បើមិនព្រមទេ នឹងត្រូវទទួលទណ្ឌកម្មនោះ គេអាចចាត់ទុកថារដ្ឋបានបញ្ជាឲ្យមានការរំលោភ ហើយទាំងបុរសទាំងស្ត្រីជាជនរងគ្រោះដោយសារគោលនយោបាយនេះ។

41. ប្រហែលដោយសារតែកង្វះខាតករណីយុត្តិសាស្ត្រនេះហើយ ទើបគុណសម្បត្តិផ្លូវច្បាប់នៃការចោទប្រកាន់លើអង្គហេតុអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះ នៅតែមានការ

ខ្ទែងគំនិតគ្នានៅតុលាការ។ នៅពេលចោទប្រកាន់ថាជា "ការរំលោភ" និងជាឧក្រិដ្ឋកម្មមួយក្រោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ អង្គបុរេជំនុំជម្រះបានកំណត់ថា ការរំលោភដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយនោះ មិនទាន់អាចបង្កើតជាទម្រង់នៃច្បាប់ទម្លាប់អន្តរជាតិក្នុងឆ្នាំ១៩៧៥-១៩៧៩ នៅឡើយទេ។ ជាលទ្ធផល ការចោទប្រកាន់លើអង្គហេតុអំពីការការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះ អាចមានលក្ខណៈសម្បត្តិត្រឹមតែជាអំពើអមនុស្សធម៌មួយក្រោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប៉ុណ្ណោះ ដែលជាហេតុបណ្តាលឲ្យមានការទទួលស្គាល់តិចតួច អំពីទម្ងន់ និងភាពលំអៀងផ្លូវភេទ ចំពោះឧក្រិដ្ឋកម្មនេះ។ ការិយាល័យសហព្រះរាជអាជ្ញា បានធ្វើញត្តិ ទៅអង្គជំនុំជម្រះសាលាដំបូងឲ្យពិចារណាចាត់ទុកការរំលោភ ជាឧក្រិដ្ឋកម្មដែលគេចាត់ទុកថាជាផ្នែកមួយនៃច្បាប់ទម្លាប់អន្តរជាតិក្នុងឆ្នាំ១៩៧៥-១៩៧៩។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានបំពេញសំណូមពរនេះ ដោយប្រើប្រាស់តុលាការឧក្រិដ្ឋកម្មសង្គ្រាមក្នុងប្រទេសចិន ជាករណីយុត្តិសាស្ត្រ។ ញត្តិនេះមិនទាន់ត្រូវបានកំណត់នៅឡើយទេ។

Perhaps due to this lack of a legal precedent, the legal qualification of the factual allegations of forced marriage is still highly contested at the Court. While indicted as “rape” and as a crime under crimes against humanity, the Pre-Trial Chamber has determined that rape as a crime against humanity did not yet form part of customary international law in 1975-1979. In the meantime the Supreme Court Chamber ruled in February 2012 that 'rape' was not a distinct crime under crimes against humanity through 1975-79. As a result, the factual allegations of forced marriage can only be qualified as an other inhuman act under crimes against humanity, affording less recognition of the gravity and sexual-basis of the crime.  It should be noted it remains the prerogative of the Trial Chamber to uphold its characterization that rape existed in 1975-79 as a distinct crime under crimes against humanity. As a result of a request from Civil Party lawyers, the OCP has petitioned the Trial Chamber to consider rape as a listed crime as part of customary international law in 1975-1979. Civil Party Lawyers completed the request using as precedent post World-War II war crimes trials in China. The motion is yet to be determined.

42. ទោះបីជាអសកម្មភាពពីដំបូងរបស់តុលាការក៏ដោយ ក៏ការបញ្ចូលបទចោទប្រកាន់លើអង្គហេតុអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជាទម្រង់នៃអំពើហិង្សាផ្លូវភេទ ក្នុងដីការបញ្ជូនរឿងទៅជំនុំជម្រះសំណុំរឿង០០២នេះ គឺជាជ័យជំនះផ្លូវច្បាប់និងផ្លូវចិត្តដ៏ធំមួយទៅហើយ។ ប៉ុន្តែជ័យជំនះនេះ មិនទាន់គ្រប់គ្រាន់ក្នុងការធានាឲ្យបានយុត្តិធម៌ សម្រាប់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលតុលាការបានទទួលស្គាល់នៅឡើយទេ ហើយជ័យជំនះនេះកាន់តែ

មានសភាពតិចតួចថែមទៀតសម្រាប់ជនរងគ្រោះពីការរំលោភក្នុងរបបខ្មែរក្រហមនេះ ដូច មាននៅក្នុងការពិភាក្សាក្នុងកថាខណ្ឌ១៥-១៧ នៅក្នុងឯកសារសង្ខេបនេះ យើងឃើញថា ការបំបែកសំណុំរឿង០០២ ទៅជាការជំនុំជម្រះតូចៗដាច់ពីគ្នា អាចជាការជំរុញមិនឲ្យមាន ការលើកយកបញ្ហាឧក្រិដ្ឋកម្មការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះ ប្រឆាំងនឹងជនត្រូវចោ ទ។ លើសពីនេះទៅទៀត ការណ៍ដែលដីកាបញ្ជូនរឿងឲ្យជំនុំជម្រះមិនបានដាក់ឲ្យជនត្រូវ ចោទទទួលខុសត្រូវ ចំពោះការរំលោភក្រៅបរិបទការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះ មានន័យថា ការរំលោភដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយនោះ នឹងមិនត្រូវបានគេ យកមកកាត់ទោសក្រៅពីឧប្បត្តិហេតុមួយដែលបានកើតឡើងនៅ ស-២១ ដែលជនត្រូវ ចោទត្រូវបានផ្តន្ទាទោសនៅក្នុងសំណុំរឿង០០១ ឡើយ។ ក្នុងន័យនេះ យើងនឹងបាត់បង់ ឱកាសក្នុងការបញ្ជូនសារ អំពីការបញ្ចប់និទណ្ឌភាពសម្រាប់ឧក្រិដ្ឋកម្មផ្លូវភេទ ទាំងក្នុង អតីតកាល ពេលបច្ចុប្បន្ន និងពេលអនាគត។

## គ. វេទិកាការស្តាប់សម្លេងពិតរបស់ស្ត្រីកម្ពុជាអំពីអំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរ ក្រហម

43. វេទិកាការស្តាប់សម្លេងពិតរបស់ស្ត្រីកម្ពុជាអំពីអំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហម ធ្វើ ឡើងនៅថ្ងៃ៧-៨ ខែធ្នូ ឆ្នាំ២០១១ នៅក្រុងភ្នំពេញ ប្រទេសកម្ពុជា ដោយមានអ្នកចូលរួម មកពីគ្រប់ទិសទីនៃប្រទេស រួមជាមួយនឹងអ្នកជំនាញអន្តរជាតិអំពីអំពើហិង្សាផ្លូវភេទពេល មានជម្លោះ។ លោកស្រី ម៉ាហ្គត វ៉លស្ត្រូម តំណាងពិសេសរបស់អគ្គលេខាធិការអង្គការ សហប្រជាជាតិ ទទួលបន្ទុកបញ្ហាហិង្សាផ្លូវភេទពេលមានជម្លោះ បានថ្លែងសុន្ទរកថាបើក វេទិកាតាមវីដេអូ ហើយសេនាធិការរបស់គាត់គឺលោកស្រី ណាន់ស៊ីអូគុប្រៃ បានធ្វើបទ បង្ហាញដ៏សំខាន់មួយ និងបានចូលរួមអង្កេតការស្តាប់សម្លេងពិតរបស់ស្ត្រីនេះពីដើមដល់ ចប់ [xxvii] ។

44. វេទិកាការស្តាប់សម្លេងពិតរបស់ស្ត្រីនេះ ត្រូវគេរៀបចំឡើងជាព្រឹត្តិការណ៍និយាយប្រាប់ ការពិតមួយមិនទាក់ទងបច្ចេកទេសតុលាការ បំពេញបន្ថែមដំណើរការនីតិវិធីស្របច្បាប់ របស់ អ.វ.ត.ក និងបានទទួលរៀបចំដោយអង្គការសិទ្ធិមនុស្សក្នុងស្រុកមួយ គឺអង្គការក្រុម អ្នកច្បាប់ការពារសិទ្ធិកម្ពុជា។ គោលបំណងនៃវេទិកានេះគឺដើម្បីផ្តល់នូវឱកាសសម្រាប់

ជនរងគ្រោះនិងសាក្សីក្នុងការទម្លាយភាពស្ងប់ស្ងៀមទាក់ទងនឹងឧក្រិដ្ឋកម្មអំពើហិង្សាផ្លូវភេទ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានរយៈពេលច្រើនទសវត្សមកហើយ ជាពិសេសក្នុងខណៈពេលដែលឧក្រិដ្ឋកម្មទាំងនេះ មិនត្រូវបាន អ.វ.ត.ក យកទៅពិចារណានៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះ។

45. វេទិកានេះ បានបង្ហាញសក្ខីកម្មចំនួនបួនពីសាក្សី/អ្នករស់រានមានជីវិត នៃឧក្រិដ្ឋកម្មផ្លូវភេទដែលបានចោទប្រកាន់។ គួរកត់សម្គាល់ថា អ្នកផ្តល់សក្ខីកម្មទីប្រាំ បានស្លាប់ប៉ុន្មានថ្ងៃមុនពេលវេទិកានេះបានប្រព្រឹត្តឡើង។

46. ពេលពិនិត្យមើលឲ្យបានគ្រប់ជ្រុងជ្រោយ យើងឃើញថាការផ្តល់សក្ខីកម្មក្នុងវេទិកានោះបញ្ជាក់បង្ហាញថា អំពើហិង្សាផ្លូវភេទ គឺជាសកម្មភាព "ប្រចាំថ្ងៃ" នៃរបបកម្ពុជាប្រជាធិបតេយ្យ, ថា វាបានកើតឡើងក្នុងបរិបទនៃការរំលោភសិទ្ធិមនុស្សទ្រង់ទ្រាយធំមួយ ប្រឆាំងនឹងជនរងគ្រោះ ដោយរួមបញ្ចូលទាំង ឃាដកម្ម អំពើទារុណកម្ម ការចាប់ខ្លួន ការធ្វើពលកម្មដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការផ្លាស់ប្តូរទីកន្លែងដោយបង្ខំ និងទម្រង់នៃអំពើឃោរឃៅធ្ងន់ធ្ងរជាច្រើនទៀត, ថា អំពើហិង្សានេះមានជនរងគ្រោះជាមនុស្សមិនទាន់គ្រប់អាយុទៀតផង, និងថា ជនដៃដល់បានសម្លាប់ឬប៉ុនប៉ងសម្លាប់ជនរងគ្រោះទៀតផង។

47. អំពើហិង្សាផ្លូវភេទ ដែលខ្មែរក្រហមបានប្រព្រឹត្តិ ដូចមានរៀបរាប់ក្នុងការផ្តល់សក្ខីកម្មនៅក្នុងវេទិកាការស្តាប់សម្លេងពិតរបស់ស្ត្រីនេះ រួមមាន ៖

    a. ការរំលោភជាលក្ខណៈប្រព័ន្ធមុនពេលសម្លាប់
    b. អំពើហិង្សាផ្លូវភេទ និងការរំលោភ ជាឧបករណ៍ធ្វើទារុណកម្ម ដើម្បីទទួលបានព័ត៌មាន ឬចម្លើយសារភាព ដើម្បីគំរាមកំហែង បង្ខំនិងដាក់ទណ្ឌកម្ម
    c. អំពើហិង្សាផ្លូវភេទ រួមមានការរំលោភច្រើនដងក្នុងអំឡុងពេលយូរមួយ ការរំលោភជាក្រុមដោយមានជនដៃដល់ច្រើន និងការរំលោភរួមដែលមានជនរងគ្រោះច្រើន
    d. ការបង្កស្នាមរបួសផ្លូវភេទបណ្តាលឲ្យមានរបួស ជួនកាលមានការបង្ហាញអំពីការប្រើវត្ថុក្នុងការរំលោភ

e. ការកាត់អវយវៈភេទ

f. ការសុខចិត្តរួមភេទដើម្បីប្តូរយកថ្នាំឬអាហារ ដែលជាមធ្យោបាយមួយក្នុងការបំពេញកាតព្វកិច្ចប្រពៃណី របស់កូនស្រីផ្តល់ជូនឪពុកម្តាយ និង

g. ការស្រាតដោយបង្ខំ និងការគំរាមរំលោភ។

48. ការផ្តល់សក្ខីកម្មនេះ បានគាំទ្រដល់ការសន្និដ្ឋានថាអំពើហិង្សាផ្លូវភេទប្រឆាំងនឹង "ខ្មាំង" បានកើតឡើងដោយគ្មានទោសពៃរ៍អ្វីឡើយ។ ឧទាហរណ៍ អ្នកផ្តល់សក្ខីកម្មម្នាក់ក្នុងវេទិកាការស្តាប់សម្លេងពិតរបស់ស្ត្រីនេះ បានរៀបរាប់ថា គាត់ជាស្ត្រីម្នាក់ក្នុងចំណោមស្ត្រី៣០នាក់ ដែលជាគោលដៅនៃការសម្លាប់ ដោយក្នុងនោះស្ត្រីនិមួយៗត្រូវគេរំលោភជាប្រព័ន្ធមុនពេលសម្លាប់។ គាត់ជាជនរងគ្រោះតែម្នាក់គត់ដែលនៅរស់រានមានជីវិត។ ការផ្តល់សក្ខីកម្មនេះក៏បានគាំទ្រដល់ការរបកគំហើញ ដែលថា បុគ្គលដែលមានការជាប់ទាក់ទងជាមួយនិងសមាសភាព "ខ្មាំង" អាចទទួលរងគ្រោះដោយអំពើហិង្សាផ្លូវភេទនេះ ដោយគ្មានទោសពៃរ៍អ្វីទាំងអស់។ ឧទាហរណ៍ អ្នកផ្តល់សក្ខីកម្មម្នាក់បានរៀបរាប់ថា គាត់ក្លាយជាគោលដៅនៃអំពើហិង្សាផ្លូវភេទនេះ ពីព្រោះគេបានចោទប្តីរបស់គាត់ជាចារកិច្ចស៊ីអាយអេ។ ដោយសារតែការជាប់ពាក់ព័ន្ធនេះ គាត់ទទួលរងការបង្ខំឲ្យស្រាតសម្លៀកបំពាក់ពីខ្លួន និងការរំលោភ។

49. ជនដៃដល់ដែលបានកំណត់នៅក្នុងការផ្តល់សក្ខីកម្មនេះ មានគ្រប់កម្រិតក្នុងជួរខ្មែរក្រហម រាប់បញ្ចូលទាំង កម្មាភិបាលថ្នាក់ខ្ពស់ ថ្នាក់កណ្តាល ថ្នាក់ទាប ក៏ដូចជាទាហាន។ មិនមានជនដៃដល់ណាម្នាក់ដែលបានរៀបរាប់ក្នុងការផ្តល់សក្ខីកម្មទាំងនេះ ដូចជាបានទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលពួកគេបានប្រព្រឹត្តឡើយ។

50. អាស្រ័យទៅលើការផ្តល់សក្ខីកម្មទាំងនោះ វាគ្មិនជំនាញមានហេតុផលក្នុងការជឿថា ទង្វើដែលបានរៀបរាប់ក្នុងការផ្តល់សក្ខីកម្មទាំងនោះ អាចបង្កើតបានជាអំពើរំលោភបំពានក្រោមច្បាប់កិច្ចព្រមព្រៀងអន្តរជាតិជាច្រើន និងជាឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិ រួមមាន ៖

a. ការរំលោភ អំពើទារុណកម្ម និងការធ្វើឲ្យក្លាយជាទាសករ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

b. អំពើហិង្សាផ្លូវភេទដែលជាអំពើអមនុស្សធម៌ផ្សេងទៀត ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

c. អំពើហិង្សាផ្លូវភេទ ជាមធ្យោបាយនៃអំពើប្រល័យពូជសាសន៍ គឺជាប្រភេទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិធ្ងន់ធ្ងរបំផុត និងត្រូវបានបញ្ចូលក្នុងច្បាប់ អ.វ.ត.ក ដែលអាចយោងដោយផ្ទាល់ទៅដល់អនុសញ្ញាបង្ការអំពើប្រល័យពូជសាសន៍ (ប្រទេសកម្ពុជាបានអនុម័តក្នុងឆ្នាំ១៩៥០)។

51. បន្ថែមលើនេះទៀត ក្នុងការដោះស្រាយនូវឧក្រិដ្ឋកម្មដែលបានចោទទាំងនេះ អ.វ.ត.ក អាចប្រើការណែនាំដែលផ្តល់ជូនពីអនុសញ្ញាស្តីពីសិទ្ធិមនុស្សជាច្រើនដូចជា អនុសញ្ញាប្រឆាំងរាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី និង អនុសញ្ញាស្តីពីសិទ្ធិកុមារ (អនុសញ្ញាទាំងពីរនេះត្រូវបានប្រទេសកម្ពុជាអនុម័តក្នុងឆ្នាំ១៩៩២), ពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងរាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី (ត្រូវបានប្រទេសកម្ពុជាអនុម័តក្នុងឆ្នាំ២០១១), ក៏ដូចជា របៀបវារៈក្រុមប្រឹក្សាសន្តិសុខស្តីពី ស្ត្រី សន្តិភាព សន្តិសុខ តាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ ១៣២៥ (២០០០), ១៨២០ (២០០៨), ១៨៨៨ (២០០៩), ១៨៨៩ (២០០៩) និង ១៩៦០ (២០១០)។

## អនុសាសន៍នៃសេចក្តីថ្លែងការណ៍របស់ក្រុមវាគ្មិននៅក្នុងវេទិកាការស្តាប់សម្លេងពិតរបស់ស្ត្រីរងគ្រោះពីអំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហម

52. យោងទៅតាមការផ្តល់សក្ខីកម្មដែលបានផ្តល់ ក្នុងអំឡុងពេលនៃវេទិកាការស្តាប់សម្លេងពិតរបស់ស្ត្រីនេះ និងយោងតាមភស្តុតាងដែលមានចំនួនកើនឡើងនោះ ក្រុមអ្នកជំនាញដែលមានអ្នកជំនាញកម្ពុជានិងអន្តរជាតិ បានធ្វើអនុសាសន៍ដើម្បីចាត់វិធានការមួយចំនួនដល់ អ.វ.ត.ក ដល់រដ្ឋាភិបាលកម្ពុជា ដល់អង្គការសហប្រជាជាតិ និងដល់ក្រុមសង្គមស៊ីវិល។

53. អនុសាសន៍ជាអាទិភាពសម្រាប់វិធានការបន្ទាន់ គឺការធ្វើតាមអាណត្តិរបស់តុលាការក្នុងការស្វែងរកយុត្តិធម៌សម្រាប់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅចន្លោះថ្ងៃ១៧មេសា១៩៧៥ និង៦មករា១៩៧៩ ក្រោមការដឹកនាំរបស់ខ្មែរក្រហម។ ក្រុមវាគ្មិនជំនាញក៏បានសង្កត់ធ្ងន់ទៅលើការស៊ើបអង្កេតឧក្រិដ្ឋកម្មផ្លូវភេទនេះជាផ្នែកមួយនៃជម្លោះ ដោយបង្កើតឲ្យមានការ

ទទួលខុសត្រូវសម្រាប់ការរំលោភបំពានក្រោមច្បាប់អន្តរជាតិ ជាពិសេសជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាឧក្រិដ្ឋកម្មសង្គ្រាម និងជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ព្រមទាំងការផ្តល់សំណងតាមការចាំបាច់។

## ក. ស្នើបអង្កេតនិងកាត់ទោសអំពើហិង្សាផ្លូវភេទប្រព្រឹត្តដោយក្រុមខ្មែរក្រហម

ដល់អង្គជំនុំជម្រះ

1) *ពង្រីកការជំនុំជម្រះដំបូងនៃសំណុំរឿង០០២ ដើម្បីបញ្ចូលការចោទប្រកាន់ពីបទការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ* ជាមធ្យោបាយក្នុងការទាញចំណាប់អារម្មណ៍ទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទាក់ទងនឹងយេនឌ័រក្នុងរបបខ្មែរក្រហម និងផ្តល់ការជួសជុលផ្នែកច្បាប់ដល់ក្រុមភាគីដើមបណ្តឹងរដ្ឋប្បវេណីធំជាងគេទីពីរ ដែលត្រូវបានទទួលស្គាល់នៅចំពោះមុខតុលាការ
2) *ពិចារណាអំពីការចោទប្រកាន់លើអង្គហេតុអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ* ជាការរំលោភ ការធ្វើឲ្យក្លាយជាទាសករ អំពើទារុណកម្ម ដ៏ដូចជាឧក្រិដ្ឋកម្មដោយឡែកមួយនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការមានផ្ទៃពោះដោយបង្ខំ ជាអំពើអមនុស្សធម៌នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ
3) *ពិចារណាឡើងវិញនូវចរិកលក្ខណៈផ្លូវច្បាប់និងការទទួលខុសត្រូវទៅលើការរកឃើញអង្គហេតុទាក់ទងនឹងការរំលោភនិងអំពើហិង្សាផ្លូវភេទក្នុងដីកាបញ្ជូនរឿងឲ្យជំនុំជម្រះសំណុំរឿង០០២* និងបញ្ចូលអំពើហិង្សាផ្លូវភេទជាមធ្យោបាយក្នុងការអនុវត្ត "គោលនយោបាយកំទេចខ្មាំង" ដែលជនត្រូវចោទត្រូវទទួលខុសត្រូវ
4) *រៀបចំចរិកលក្ខណៈឡើងវិញអំពី ការរំលោភឲ្យទៅជាឧក្រិដ្ឋកម្មមួយ* ក្រោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដើម្បីនាំយកយុត្តិធម៌សម្រាប់ឧក្រិដ្ឋកម្មក្នុងអតីតកាល និងដើម្បីធ្វើជារនាំងមិនឲ្យកើតឡើងវិញនូវអំពើហិង្សាផ្លូវភេទ ក្នុងពេលបច្ចុប្បន្ន និងក្នុងពេលអនាគត។ ប្រើករណីយុត្តិសាស្ត្រនៃតុលាការឧក្រិដ្ឋកម្មសង្គ្រាមក្រោយសង្គ្រាមលើកទី២ ក្នុងប្រទេសចិន កូរ៉េ និងឥណ្ឌូណេស៊ី ដែលបាន

ចារិកលក្ខណៈនៃការរំលោភជាឧក្រិដ្ឋកម្មដោយឡែកមួយក្រោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាផ្នែកនៃច្បាប់ទម្លាប់។

ដល់ការិយាល័យសហចៅក្រមស៊ើបអង្កេត

5) ***ស៊ើបអង្កេតឲ្យបានពេញលេញដោយមានការយកចិត្តទុកដាក់ដូចគ្នាដូចដែលការស៊ើបចំពោះឧក្រិដ្ឋកម្មផ្សេងទៀតនៅ ចំពោះមុខតុលាការបានទទួល*** ពេញគ្រប់កាលៈទេសៈនិងតួអង្គនៃអំពើហិង្សាផ្លូវភេទក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤

6) ***បញ្ចូលសំណួរជាក់លាក់មួយចំនួនសម្រាប់ការស៊ើបអង្កេតសម្រាប់សំណុំរឿង ០០៣ និង០០៤ ទាក់ទងនឹងអំពើហិង្សាផ្លូវភេទ*** (ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្រោមសមត្ថកិច្ចរបស់ជនសង្ស័យក្នុងសំណុំរឿង០០៣ និង០០៤ ការកាត់អវយវៈភេទ ការគំរាមកំហែងផ្លូវភេទ ការរំលោភ និងការរំលោភបំពានដទៃទៀត ដែលគេប្រើប្រឆាំងនឹង "ខ្មាំង" ដែលពួកគេបានកំណត់)

## ខ. បង្កើតយន្តការសម្រាប់ការទទួលស្គាល់និងការផ្តល់សំណងសមរម្យសម្រាប់ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហម

ដល់ស្ថាប័ន អ.វ.ត.ក ៖

1) **រៀបចំបង្កើតនិងអនុវត្តយន្តការជម្រើសផ្សេងមិនទាក់ទងបច្ចេកទេសតុលាការ** សម្រាប់យុត្តិធម៌អន្តរកាល ដូចមានកំណត់អាណត្តិក្នុងផ្នែកគាំទ្រជនរងគ្រោះក្រោមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដោយរាប់បញ្ចូលទាំង ការផ្សះផ្សារ ការរំលឹកការចងចាំ និងការស្វែងរកការពិត និងជម្រើសផ្សេងៗទៀត ដើម្បីលើកកម្ពស់ និងគាំទ្រដល់ការទទួលយកជាផ្លូវការ ការទទួលស្គាល់ និងការបញ្ចូលបទពិសោធន៍របស់សាក្សីនិងអ្នករស់រានមានជីវិតនៃអំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហម

2) ***ធានាថាតម្រូវការរបស់ជនរងគ្រោះគឺជាចំណែកសំខាន់នៃការផ្តល់សំណងដែលមានលក្ខណៈរំញោចយេនឌ័រ*** ដោយរួមមានទាំង ការផ្តល់សេវាថែទាំសុខភាព

ការអប់រំ ការបណ្តុះបណ្តាល និងកម្មវិធីសិក្សាអំពីប្រវត្តិសាស្រ្តនៃវិនាសកម្មក្នុងរបបខ្មែរក្រហមដោយរួមបញ្ចូលទាំងអំពើហិង្សាផ្លូវភេទដែរ។

ដល់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា, អ.វ.ត.ក និងអង្គការសហប្រជាជាតិ ៖

3) ***ធ្វើការរួមគ្នាដើម្បីបង្កើតមូលនិធិថ្នាក់ជាតិមួយសម្រាប់ការផ្តល់សំណងសម្រាប់ជនរង គ្រោះពីអំពើហិង្សាផ្លូវភេទ*** ក្នុងអំឡុងពេលរបបខ្មែរក្រហម ក្នុងគោលបំណងដើម្បីអនុលោមតាមកាតព្វកិច្ចដូចមានចែងក្នុងមាត្រា១៦ នៃគោលការណ៍និងការណែនាំជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិទទួលបានការជួសជុលនិងសំណងសម្រាប់ជនរងគ្រោះនៃការបំពារបំពានធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការបំពារបំពានធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលបានអនុម័តនិងប្រកាសដោយសេចក្តីសម្រេចមហាសន្និបាត ៦០/១៤៧ ថ្ងៃទី១៦ ធ្នូ ២០០៥

*4)* ***ជំរុញសមត្ថភាពយេនឌ័រ និងធ្វើឲ្យប្រសើរឡើងដល់តុល្យភាពយេនឌ័រក្នុង អ.វ.ត.ក***

រដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ៖

5) ***តែងតាំងស្រ្តីដែលមានគុណសម្បត្តិគ្រប់គ្រាន់ទៅក្នុងតួនាទីធ្វើការសម្រេចចិត្តនៅក្នុងតុលាការ*** ដោយមានចំណេះដឹងគ្រប់គ្រាន់អំពីលក្ខណៈនៃឧក្រិដ្ឋកម្មផ្លូវភេទ ថាតើឧក្រិដ្ឋកម្មបែបនេះគួរត្រូវស៊ើបអង្កេតនិងកាត់ទោសរបៀបណាទើបសមរម្យ ព្រមទាំងថាតើត្រូវផ្តល់ការគាំទ្រចិត្ត-សង្គមបែបណា ទើបជាការប្រសើរបំផុតសម្រាប់ជនរងគ្រោះ និងសាក្សី

ដល់អង្គការសហប្រជាជាតិ ៖

6) ***ផ្តល់មូលនិធិនិងចាត់តាំងទីប្រឹក្សាជំនាញយេនឌ័រថ្នាក់ខ្ពស់ម្នាក់ឲ្យទៅ អ.វ.ត.ក ជាមួយដៃគូជាតិម្នាក់*** ដើម្បីតស៊ូមតិពីក្នុងតុលាការមកដើម្បីឲ្យមានការដាក់បញ្ចូលទស្សនៈយេនឌ័រនិងការយកចិត្តទុកដាក់លើយេនឌ័រ ចូលទៅក្នុងអំពើហិង្សាផ្លូវភេទ និងយេនឌ័រ ជាចំណុចស្នូលនៅរាល់គ្រប់ទិដ្ឋភាពទាំងអស់នៃ

ដំណើរការនីតិវិធី និងដើម្បីធានាថាបញ្ហាទាំងអស់នេះ គឺជាចំណែកនៃកេរដំណែលរបស់ អ.វ.ត.ក ដល់នីតិរដ្ឋថ្នាក់ជាតិ។

ដល់ស្ថាប័ន អ.វ.ត.ក

7) ***ជ្រើសរើសនិងបន្តរក្សាទុកបុគ្គលិកស្ត្រីដែលទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់សម្រាប់ការស៊ើបអង្កេត ការសួរសំណួរ និងការបកប្រែប្រធានបទទាក់ទងនឹងអំពើហិង្សាផ្លូវភេទនេះ*** និងដើម្បីបង្កើតវិធានការជាក់លាក់មួយចំនួនសម្រាប់ផ្តល់ឲ្យមាននូវ សន្តិសុខ ភាពថ្លៃថ្នូរ ការសម្ងាត់ និងការប៉ះទង្គិចផ្លូវចិត្តដល់ជនរងគ្រោះ។

[i] បណ្ឌិត ថេរេសាដឺឡង់ហ្គីស ជាអ្នកជំនាញជាន់ខ្ពស់ផ្នែកសិទ្ធិស្ត្រីពេលមានជម្លោះ និងជាអ្នកសម្របសម្រួលការងារក្នុងវេទិកាការស្តាប់សម្លេងពិតរបស់ស្ត្រី មានតួនាទីជាអ្នកនិពន្ធនាំមុខសម្រាប់ឯកសារសង្ខេបនេះ រួមនិពន្ធ ដោយមានជំនួយច្បាប់បច្ចេកទេពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក លោកស្រី ស៊ីខេស្វូដហ្ស៊ីនស្គី។ សូមអរគុណដល់ ក្លែរដាហ្វី អ្នកសង្កេតការណ៍តុលាការខ្មែរក្រហមនៃអង្គការគម្រោងផ្តួចផ្តើមយុត្តិធម៌សង្គមសេរី សម្រាប់ការពិនិត្យឡើងវិញដោយប្រុងប្រយ័ត្ននិងការឆ្លើយតបដោយគំនិតល្អៗជាច្រើនទៅលើទឡ្ហីករណ៍ដូចមាននៅក្នុងឯកសារនេះ

[ii] ទាក់ទងនឹងសារតាទាំងស្រុងក្នុងការបង្កើតអ.វ.ត.ក សូមអាន *តុលាការខ្មែរក្រហម* បណ្ណាធិការដោយ ចនឌីស៊ីអស៊ីអារីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា, ភ្នំពេញ (ស៊េរីឯកសារ No. 10, 2006)

[iii] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (២០០៤), ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ, ច្បាប់វិសោធនកម្ម, http://www.eccc.gov.kh/sites/default/files/legal-documents/KR_Law_as_amended_27_Oct_2004_Eng.pdf, Ch 1, p. 1 – 3.

[iv] ការសម្ភាសផ្ទាល់ខ្លួនជាមួយបុគ្គលិកអង្គការសហប្រជាជាតិ ដោយផ្អែកលើទិន្នន័យអង្គការសហប្រជាជាតិ និងជាមួយមេធាវីមិនមែនជាបុគ្គលិកអង្គការសហប្រជាជាតិធ្វើការនៅតុលាការ។ សម្រាប់ព័ត៌មានបន្ថែមអំពីចៅក្រម ព្រះរាជអាជ្ញា និងបុគ្គលផ្សេងទៀត សូមមើលគេហទំព័រ អ.វ.ត.ក http://www.eccc.gov.kh/en (បើកមើលនៅថ្ងៃទី២២ មករា ២០១២).

[v] សូមអាន ខាទ្រីណាអេនដឺសុន "បង្វិលចង្កូត នៃការផ្សះផ្សា ត្រឡប់មកវិញ ៖ ការឆ្លើយតបចំពោះអំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហម" នៅក្នុង *ព្រឹត្តិប័ត្រស្រាវជ្រាវដើម្បីយុត្តិធម៌សង្គមស៊ីអាថល* (ច្បាប់ទី៣ លេខ២ ឆ្នាំ២០០៥) ទំព័រ៧៨៥-៨៣២ ក្នុងនោះ គាត់បានពិភាក្សាអំពីលទ្ធផលទាយទុកមុនដោយសារតែកង្វះខាតសមត្ថភាពស្តីពីអំពើហិង្សាផ្លូវភេទក្នុងតុលាការ រួមជាមួយនឹងការខកខានមិនបានធ្វើការស៊ើបអង្កេតដែលមានសក្តានុពល ក្នុងខណៈពេលដែល អ.វ.ត.ក នៅក្នុងដំណាក់បង្កើតកាលរៀបចំនៅឡើយ

[vi] សម្រាប់ព័ត៌មានបន្ថែមអំពីផលប៉ះពាល់ពិសេសរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី រាប់ទាំងការនាំយកឲ្យតុលាការមានចំណាប់អារម្មណ៍ទៅលើបញ្ហាអំពើហិង្សាផ្លូវភេទ សូមអានទឡ្ហីករណ៍សន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលសំណុំរឿង០០១របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី រាយការណ៍ដោយ ដេវីដស្កេហ្វឺ *អ្នកឃ្លាំមើលតុលាការខ្មែរក្រហមកម្ពុជា* ២៨ វិច្ឆិកា ២០០៩ ទំព័រ ៤-៦ (បើកចូលថ្ងៃទី២៣ មករា ២០១២) ក្នុងhttp://www.cambodiatribunal.org/sites/default/files/ctm_blog_11-23-2009.pdf). សម្រាប់ការវិភាគទាក់ទងនឹងសិទ្ធិនិងតួនាទីដែលកាន់តែខើចទៅៗក្នុងការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក សូមអាន ជូលៀរ៉ែលឡេស "ភាគីដើមបណ្តឹងរដ្ឋប្បវេណីកំពុងបរាជ័យក្នុងប្រទេសកម្ពុជា" វិទ្យុហ្វូឡង់អន្តរជាតិ ១៨ មករា២០១២ បើកចូលថ្ងៃទី២២ មករា ២០១២ ក្នុង http://www.cambodiatribunal.org/sites/default/files/news/Losing%20Civil%20Parties%20in%20Cambodia.pdf. សូមអាន *ស្លាកស្នាមបិទបាំងរបស់កម្ពុជា៖ ចិត្តវិទ្យានៃការប៉ះទង្គិចផ្លូវចិត្តពីរបបខ្មែរក្រហម* បណ្ណាធិការដោយ បេថវ៉ាន់ស្វាក ដារីនរេឆេទី និងយក់ឆាង ដោយមាន អធឹមថាល់បុត ជាបណ្ណាធិការគ្រប់គ្រង, មជ្ឈមណ្ឌលឯកសារកម្ពុជា, ភ្នំពេញ (២០១១) ជាពិសេសផ្នែកទី២៖ "ផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្តលើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ទំព័រ ៩២-១៩០។ ទោះជាមិនមានការពិភាក្សាជាពិសេសអំពីបទពិសោធន៍នៃអំពើហិង្សាផ្លូវភេទក៏ដោយ ក៏របកគំហើញដែលថា ដំណើរការនីតិវិធី អ.វ.ត.ក អាចរួមចំណែកដល់ការប៉ះទង្គិចផ្លូវចិត្តបន្ថែមទៀត ក៏ដូចជាឱកាសសម្រាប់ការព្យាបាលនោះ នៅតែមានភាពទាក់ទង។

[vii] សម្រាប់ព័ត៌មានបច្ចុប្បន្នភាពកើតឡើងក្នុងដំណើរការនីតិវិធី និងសកម្មភាព អ.វ.ត.ក សូមមើល *អ្នកឃ្លាំមើលតុលាការខ្មែរក្រហម* រៀបចំដោយមហាវិទ្យាល័យច្បាប់នៃសកលវិទ្យាល័យណសវ៉េស្ទឺន និងមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុង http://www.cambodiatribunal.org/ (បើកចូលថ្ងៃទី២៣ មករា ២០១២)។ អ.វ.ត.ក ក៏មានគេហទំព័រដែលមានការផ្សាយបន្តផ្ទាល់ ឯកសារតុលាការ ប្រតិទិន និងរបៀបវារៈអង្គជំនុំជម្រះសាលាដំបូង ក្នុង http://www.eccc.gov.kh/en (បើកចូលថ្ងៃទី ១៩ មករា ២០១២)

[viii] "Final Judgment", 3 February 2012, doc no. F28,  paragraphs 174- 183.

[ix] "សហរដ្ឋអាមេរិចប្រកាសអំពីការចូលរួមចំណែកទៅដល់តុលាការខ្មែរក្រហម" សេចក្តីថ្លែងព័ត៌មានរបស់ការិយាល័យកិច្ចការឧក្រិដ្ឋកម្មសង្គ្រាម ក្រសួងការពារជាតិសហរដ្ឋអាមេរិច ថ្ងៃ១៤ តុលា ២០១១ http://www.state.gov/j/gcj/us_releases/other/175540.htm (បើកចូលថ្ងៃទី២២ មករា ២០១២)។

[x] សូមអាន វិទ្យាស្ថានបើកទូលាយ *ការអភិវឌ្ឍថ្មីៗនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* ថ្ងៃទី១ វិច្ឆិកា ២០១១, ក្នុង http://www.unhcr.org/refworld/docid/4ed781272.html (បើកចូលថ្ងៃទី២៣ មករា ២០១២) និងអង្គការឃ្លាំមើលសិទ្ធិមនុស្ស *កម្ពុជា៖ ចៅក្រមស៊ើបអង្កេតឧក្រិដ្ឋកម្មខ្មែរក្រហមគួរលាលែងតំណែង* ថ្ងៃទី៣ តុលា ២០១១, ក្នុង http://www.unhcr.org/refworld/docid/4e8ab2a52.html (បើកចូលថ្ងៃទី២៣ មករា ២០១២)។ សូមមើល ម៉ាកអ៊ែលីស *ការការពារឯករាជភាពតុលាការក្នុងតុលាការកូនកាត់៖ មេរៀនទទួលបានពី អ.វ.ត.ក និងការអនុវត្តល្អបំផុតសម្រាប់ពេលអនាគត* (សមាគមមេធាវីអន្តរជាតិ, ខែកញ្ញា ២០១១)

[xi] សូមអាន "របបខ្មែរក្រហម ភាពខុសពីធម្មតានៃអំពើហិង្សាផ្លូវភេទ" *ខេមបូឌាដេលី* ថ្ងៃ១២-១៤ កញ្ញា ២០១១ (ទំព័រ១១) ដែលគេបានដកស្រង់សម្តីរបស់ចៅក្រមស៊ីលវ៉ាខាតវ៉ាយថា "ជម្លោះមួយនេះមានភាពខុសពីធម្មតា ដោយវាមិនមានការចោទប្រកាន់ទៅលើអំពើហិង្សាគ្រប់ទីកន្លែងទៅលើស្ត្រីដោយសារតែពួកគេជាស្ត្រី"។ នៅក្នុងការសរសេរឆ្លើយតបទៅបណ្ណាធិការកាសែតនោះ លោកស្រី ស៊ិនសុវន មេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីជាតិនិងលោកស្រី ស៊ីខេស្វូតហ្ស៊ីនស្គីមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិបានឆ្លើយជំទាស់ថា "គោលនយោបាយខ្មែរក្រហមអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលជាទម្រង់ហិង្សាយេនឌ័រ ត្រូវគេអនុវត្តយ៉ាងទូលាយនិងជាប្រព័ន្ធ"។ ចុងក្រោយ ឧក្រិដ្ឋកម្មនេះត្រូវគេបញ្ចូលក្នុងដីកាបញ្ជូនរឿងឲ្យជំនុំជម្រះសំណុំរឿង០០២ ក្រោមកិច្ចប្រឹងប្រែងរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ហើយ "ជនរងគ្រោះដែលមានភាពក្លាហានក្នុងការនិយាយអំពីឧក្រិដ្ឋកម្មនិងការឈឺចាប់ដែលពួកគេបានទទួលរង"

[xii] សូមមើល ដីកាដំណោះស្រាយសំណុំរឿង០០២, ក្នុង http://www.eccc.gov.kh/sites/default/files/documents/courtdoc/D427Eng.pdf (បើកចូលថ្ងៃទី២២ មករា២០១២)។ ជាពិសេសសូមមើលកថាខណ្ឌ១៤២៦-១៤២៩ ដែលបានបញ្ជាក់ថា "នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ការរំលោភដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានប្រព្រឹត្តិឡើងក្នុងកាលៈទេសៈផ្សេងគ្នាជាច្រើន ជាពិសេសក្នុងមន្ទីរសន្តិសុខ" (កថាខណ្ឌ ១៤២៦) ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា "គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាជាផ្លូវការទាក់ទងនឹងការរំលោភគឺដើម្បីបង្កាកុំឲ្យកើតមានឡើង និងដើម្បីដាក់ទណ្ឌកម្មជនដៃដល់។ ទោះបីជាគោលនយោបាយនេះមិនអាចគ្រប់គ្រងមិនឲ្យមានការរំលោភក៏ដោយ ក៏គេមិនអាចចាត់ទុកថាការរំលោភជាឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មដែលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ប្រើដើម្បីអនុវត្តដើម្បីសម្រេចគោលបំណងរួមដែរ" (កថាខណ្ឌ ១៤២៩)។

[xiii] ការសម្ភាសផ្ទាល់ខ្លួនជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ស៊ីខេស្វូតហ្ស៊ីនស្គី នៅថ្ងៃ៥ កុម្ភៈ ២០១២ នៅភ្នំពេញ, កម្ពុជា

[xv] ការបកប្រែសីលធម៌ប្រការទី៦ដែលគេឧស្សាហ៍យកមកនោះ បានបោះពុម្ពក្នុង "សីលធម៌ប្រការទី៦" ដោយលោកយក់ឆាង *ទស្សនាវត្តីស្វែងរកការពិត* មជ្ឈមណ្ឌលឯកសារកម្ពុជា ភ្នំពេញ លេខ១៥ (២០០១)

http://d.dccam.org/Projects/Magazines/Previous%20Englis/Issue15.pdf (បើកចូលថ្ងៃទី៣១ ធ្នូ ២០១១)។ ការបកប្រែដែលមានការផ្សព្វផ្សាយយ៉ាងទូលាយនេះ មានភាពមិនច្បាស់លាស់ទាល់តែសោះ ដោយសារការសន្មត់ថា ទង្វើ "ដែលមានការយល់ព្រម" អាចជាទង្វើ "ត្រូវគេបង្ខំ"។ ក្នុងភាសាខ្មែរ មានតែមួយប្រយោគប៉ុណ្ណោះ ប៉ុន្តែការបកប្រែ សីលធម៌ប្រការទី៦នេះ មានពីរបើកថាខណ្ឌជាភាសាអង់គ្លេស។ អ្នកបកប្រែជាន់ខ្ពស់ម្នាក់នៅតុលាការបានបកប្រែក្រៅផ្លូវការថា៖

៦. កុំប្រព្រឹត្តិអំពើមិនត្រឹមត្រូវតាមសីលធម៌លើស្ត្រីឲ្យសោះ

ជាការសន្និដ្ឋាន កុំប្រព្រឹត្តិអំពើមិនត្រឹមត្រូវតាមសីលធម៌លើស្ត្រីនិងបុរសឲ្យសោះ។ កិត្តិយសរបស់យើង ឥទ្ធិពលបដិវត្តរបស់យើង វប្បធម៌ថ្លៃថ្នូរនិងស្អាតស្អំរបស់ប្រជាជនយើង និងត្រូវប៉ះពាល់ប្រសិនបើអំពើទាំងនេះត្រូវបានប្រព្រឹត្ត។ ម្យ៉ាង វាប៉ះពាល់ដល់ប្រជាជនយើង។ ម្យ៉ាងវិញទៀត និងសំខាន់បំផុតនោះ ប្រសិនបើយើងប្រព្រឹត្តិអំពើមិនត្រឹមត្រូវតាមសីលធម៌លើស្ត្រីនិងបុរស ដែលជាសមាសភាពប្រាសចាកសីលធម៌បំផុតដែលមានតែពួកខ្មាំងគ្រប់ប្រភេទទេដែលធ្វើបែបនេះ នោះយើងនឹងត្រូវខ្មាំងអូសទាញងាយស្រួលបំផុត។ ដូច្នេះ ទង្វើនេះជាទង្វើគ្រោះថ្នាក់ចំពោះយើងទាំងអស់គ្នា និងចំពោះចលនាបដិវត្ត។

មិនមានឧបសគ្គអ្វីទាក់ទងដល់ការរៀបចំការរៀបអាពាហ៍ពិពាហ៍នាពេលបច្ចុប្បន្ននេះទេ ប្រសិនបើអនុវត្តបានតាមគោលការណ៍ខាងក្រោមនេះ៖

ទីមួយ៖ ជនត្រូវរៀបការនិមួយៗត្រូវយល់ព្រមក្នុងការរៀបអាពាហ៍ពិពាហ៍ និង

ទីពីរ៖ មានការអនុម័តពីសហាករ

ពេលអនុវត្តតាមគោលកាណ៍នេះហើយ មិនមានហេតុផលណាមួយសម្រាប់ជនណាម្នាក់ក្នុងការប្រព្រឹត្តិអំពើអសីលធម៌លើស្ត្រីនិងបុរស ឡើយ។

ខណៈពេលដែលពាក្យ "អំពើមិនត្រឹមត្រូវតាមសីលធម៌" អាចបកបកប្រែថាជា អំពើអសីលធម៌ ដោយរាប់ទាំងទំនាក់ទំនងផ្លូវភេទដែលមិនមានការយល់ព្រមដែរនោះ ជាទូទៅ គេយល់ថា សូម្បីតែទំនាក់ទំនងផ្លូវភេទដែលមានការយល់ព្រមគ្នារវាងបុរសនិងស្ត្រី ដែលរៀបការដោយមិនមានការរៀបចំដោយ *អង្គការ* ក៏ត្រូវពួកខ្មែរក្រហមគិតថាជា អំពើមិនត្រឹមត្រូវតាមសីលធម៌ ឬ អំពើអសីលធម៌ ដែរ។ ជាការគួរឲ្យចាប់អារម្មណ៍ក្នុងការកត់សម្គាល់ថា ពីរបៀបដែល សីលធម៌ប្រការទី៦នោះប្រើសកម្មភាពផ្លូវភេទ ដើម្បីញែក "ខ្មាំង" និង ក្នុងន័យនេះ អាចត្រូវគេចាត់ទុកថាជាចំណុលស្នូល សម្រាប់ "គោលនយោបាយកំទេចខ្មាំង" ជាជាង បំបែកចេញ ដែល អ.វ.ត.ក បានកំណត់។

[xvi] សូមអាន ខាទ្រីណាអេនដឺសុន "បង្វិលចង្កូត នៃការផ្សះផ្សា ត្រឡប់មកវិញ ៖ ការឆ្លើយតបចំពោះអំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហម" នៅក្នុង *ព្រឹត្តិប័ត្រស្រាវជ្រាវដើម្បីយុត្តិធម៌សង្គមស៊ីអាថល* (លេខ៧៨៥ ឆ្នាំ២០០៥) ទំព័រ៧៨៩។ សូមអាន ខាទ្រីណាណាតាលី "ខ្ញុំអាចមានអារម្មណ៍ថាព្រលឹងរបស់ខ្ញុំបានហោះហើរចេញពីក្នុងរាងកាយរបស់ខ្ញុំ៖ ការស្រាវជ្រាវអំពីអំពើហិង្សាទាក់ទងយេនឌ័រ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅខេត្តបាត់ដំបង និងខេត្តស្វាយរៀង" សម្រាប់អង្គការគំពោងអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ចេញផ្សាយក្នុងពេលខាងមុខ។

[xvii] អេលីហ្សាបេថបែ៊កឃី *ពេលសង្គ្រាមផុតរលត់ទៅ៖ កម្ពុជានិងបដិវត្តខ្មែរក្រហម,* កិច្ចការសាធារណៈ, ក្រុងញូវយ៉ក, ១៩៩៨, ទំព័រ១៨៤។ ទឡ្ហីករណ៍របស់គាត់លើកឡើងថា មានចំណងរវាងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ភាពខ្ពស់នៃជាតិសាសន៍ និងការផលិត។

[xviii] សូមអានដំណោះស្រាយសំណុំរឿង០០២ កថាខណ្ឌ ១៤២៩ ក្នុង http://www.eccc.gov.kh/sites/default/files/documents/courtdoc/D427Eng.pdf (បើកចូលថ្ងៃទី២២ មករា ២០១២).

[xix] សូមអាន ម៉ម កល្យានី *"រំលោភស្ត្រីដែលជាខ្មាំងអង្គការ" ទស្សនាវត្តីស្វែងរកការពិត*។ មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ១៥ (២០០១) ទំព័រ ២-៥ និង ៦០-៦០។

[xx] អេនជីសុន "បង្វិលចង្កូត នៃការផ្សះផ្សា ត្រឡប់មកវិញ" ទំព័រ៧៨៩-៧៩០

[xxi] ក្រៅពីប្រភពដែលដកស្រង់មកប្រើក្នុងឯកសារនេះ សូមអាន ទ្រូឌីចាកុបសិន *ភាពជាទេពធីតាដែលបាត់បង់ទៅ៖ ការបដិសេធមិនទទួលអំណាចស្ត្រីក្នុងប្រវត្តិសាស្ត្រកម្ពុជា* (ទីភ្នាក់ងារNIAS Press: ក្រុងខូផេនហាហ្គេន, ២០០៨), ណាកាហ្គាវ៉ាកាស៊ុមី *អំពើហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម៖ រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)* (n.p.: ភ្នំពេញ, ២០០៨), ហ្សារីណាស្វូ *ស្បៃគ្របក្បាលរបស់កម្ពុជា៖ ការចងចាំរបស់ស្ត្រីចាមមូស្លីមក្រោយរបបខ្មែរក្រហម* (មជ្ឈមណ្ឌលឯកសារកម្ពុជា, ភ្នំពេញ, ២០០១), និងភាពយន្តដោយ ផាត់រចនា *វាលស្រែក្នុងរបបខ្មែរក្រហម៖ រឿងរ៉ាវរបស់អ្នករស់រានជីវិតពីការរំលោភ តាំងគីម* (មជ្ឈមណ្ឌលឯកសារកម្ពុជា, ភ្នំពេញ, ២០០៤)។

[xxii] សូមអានដីកាដំណោះស្រាយសំណុំរឿង០០២ ក្នុង
http://www.eccc.gov.kh/sites/default/files/documents/courtdoc/D427Eng.pdf (បើកចូលថ្ងៃទី២២ មករា ២០១២)។

[xxiii] សូមអាន ទឡ្ហីករណ៍សន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីកម្ពុជាគង់ពិសី ដូចមានរាយការណ៍ក្នុង *អ្នកឃ្លាំមើលតុលាការកម្ពុជា* ថ្ងៃទី២៨ វិច្ឆិកា ២០០៩ ដោយដេវីដស្កេហ្វ៊ី, ទំព័រ ៤-៦ (បើកចូលថ្ងៃទី២៣ មករា ២០១២ ក្នុងhttp://www.cambodiatribunal.org/sites/default/files/ctm_blog_11-23-2009.pdf)។

[xxiv] សូមអានដីកាដំណោះស្រាយសំណុំរឿង០០២, កថាខណ្ឌ១៤២៨ ក្នុង
http://www.eccc.gov.kh/sites/default/files/documents/courtdoc/D427Eng.pdf (បើកចូលថ្ងៃទី២២ មករា ២០១២)។

[xxv] សូមអាន ម៉មកល្យានី ក្នុងអត្ថបទ "ភស្តុតាងអំពីការរំលោភបំពានផ្លូវភេទក្នុងរបបកាន់អំណាចរបស់កម្ពុជាប្រជាធិបតេយ្យ" *ទស្សនាវដ្តីស្វែងរកការពិត*, មជ្ឈមណ្ឌលឯកសារកម្ពុជា, ភ្នំពេញ, លេខ១៥ (២០០១) ដែលគាត់បានសន្និដ្ឋានថា "នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ច្បាប់ដែលតាក់តែងឡើងដើម្បីហាមប្រាមការរំលោភបំពានផ្លូវភេទ ប៉ុន្តែបែរជាជំរុញឲ្យមានការរំលោភបំពានផ្លូវភេទទៅវិញ" (៥) ហើយ "ច្បាប់បង្កើតឡើងយ៉ាងរបៀបនេះដែលធ្វើឲ្យស្ត្រីគ្មានទទួលអ្វីពីការនិយាយនោះទេ" អំពីការរំលោភ ប៉ុន្តែអាចនិងត្រូវទទួលការសងសឹកទៅវិញទេ (៥)។

[xxvi] សូមអាន ផេកឡឺវីន *ស្នេហានិងភាពញ៉ូវខ្លាចក្នុងប្រទេសកម្ពុជា៖ អាពាហ៍ពិពាហ៍ កំណើត និងការឈឺចាប់ជាពិធី ក្រោមរបបខ្មែរក្រហម* (ទីភ្នាក់ងារ NUS Press: សាំងហ្គាពួរ, ២០១០) និង*ភាពជាទេពធីតាដែលបានបាត់បង់ទៅ*របស់ទ្រូឌីចាកុបសិន សម្រាប់ការវិភាគផលប៉ះពាល់យេនឌ័រនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ព្រមទាំងការបាត់បង់ស្ថាប័នសង្គម និងពិធីដែលស្ត្រីទទួលបានអត្តសញ្ញាណនិងឋានៈ។

[xxvii] សូមអាន "អ្នកធ្វើយុទ្ធនាការបានលើកជាទឡ្ហីករណ៍ថា អនាគតកម្ពុជាត្រូវពឹងទៅលើការដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មផ្លូវភេទក្នុងអតីតកាល" ដោយហាណាហ៊ិនស្ត្រម ក្នុងThe Guardian, ថ្ងៃទី១៦ ធ្នូ ២០១១ ក្នុង
http://www.guardian.co.uk/global-development/2011/dec/16/cambodia-past-sexual-crimes-khmer-rouge (បើកចូលថ្ងៃទី១៩ មករា ២០១២)